# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




Asian International Justice Initiative (AIJI),a project of East-West Center and UC Berkeley War Crimes Studies Center

*"....ពួកប្រតិកិរិយា ពួករាជវង្សអីពួកសក្តិភូមិខ្លះក៏គេមានស្មារតីស្នេហាជាតិដែរ មិនមែនចេះតែក្បត់ជាតិទាំងអស់ឯណាបើអាណាក៏សត្រូវៗ បើអីចឹងជាតិយើង វាបែកបាក់ខ្ទេចខ្ទីអស់ហើយ។"*

**-ជនជាប់ចោទ នួន ជា**

## *ជំពូកទី១ ៖* ទិដ្ឋភាពទូទៅ

បន្ទាប់ពីសវនាការបានសម្រាកអស់រយៈពេលបីសប្តាហ៍ អង្គជំនុំជម្រះបានបន្តនីតិវិធីស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីលោក **ក្លាន ហ្វីត** និងលោក **រម៉ម យុន** ព្រមទាំងជនជាប់ចោទពីររូបទៀត គឺលោក **នួន ជា** និងលោក **ខៀវ សំផន** ។ វាជាសប្តាហ៍មួយដែលត្រូវបានរំខានដោយភាពតានតឹង ដែលកើតចេញពីបុគ្គលិកលក្ខណៈនៃការជជែកឆ្លើយឆ្លងគ្នានៅក្នុងបន្ទប់សវនាការ។ អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម បានធ្វើរបាយការណ៍លើបញ្ហាផ្លូវច្បាប់ និងនីតិវិធីដែលបានកើតឡើងសប្តាហ៍នេះ ហើយក៏បានអង្កេតតាមដានមើលនូវការទទួលយកភស្តុតាងឯកសារ និងសក្ខីកម្មដែលទាក់ទងនឹងប្រវត្តិកម្ពុជាប្រជាធិបតេយ្យផងដែរ។

លោក **ក្លាន ហ្វីត** និងលោក **រម៉ម យុន** បានបញ្ចប់ការផ្តល់សក្ខីកម្មរបស់ពួកគាត់ដោយធ្វើអត្ថាធិប្បាយ ពីបទពិសោធន៍ជាកម្មាភិបាលនៃបក្សកុម្មុយនីស្តកម្ពុជា ការបានជួបផ្ទាល់ជាមួយនឹងជនជាប់ចោទ បទពិសោធន៍នៃការជាប់ឃុំឃាំងនៅកន្លែងដាច់ដោយឡែកពីគ្នា ព្រមទាំងការបង្ខំឲ្យធ្វើការងាររហូតដល់ចុងបញ្ចប់នៃរបបនេះ។ ចំណែកលោក **នួន ជា** វិញ បានផ្តល់សក្ខីកម្មពីប្រវត្តិរឿងរ៉ាវពីដើមដំបូងរបស់បក្សកុម្មុយនីស្តកម្ពុជារហូតឈានដល់ការធ្វើផែនការជម្លៀសទីក្រុងភ្នំពេញ។ ជាញឹកញាប់ ការផ្តល់សក្ខីកម្មរបស់គាត់មានការយឺតយ៉ាវ ដោយសារ

ជនជាប់ចោទបានទទូចជាច្រើនដងសុំមើលឯកសារដើម នៅពេលមានការដាក់បង្ហាញឯកសារភស្តុតាងក្នុងអង្គហេតុណាមួយនៅចំពោះមុខគាត់ ហើយសុំឲ្យគាត់ធ្វើការបញ្ជាក់។ អង្គជំនុំជម្រះបានសម្រេចថា វាជាបញ្ហានីតិវិធីភាគីត្រូវយោងទៅលើឯកសារចម្លងក្នុងប្រព័ន្ធអេឡិចត្រូនិច ដែលមាននៅក្នុងសំណុំឯកសាររបស់តុលាការនេះលុះណាតែយថាភាពនៃឯកសារណាមួយដែលត្រូវដាក់បង្ហាញនោះ ត្រូវបានជំទាស់តវ៉ាពីភាគីដទៃទៀត។

ទោះជាយ៉ាងនេះក្តី លោក **នួន ជា** នៅតែទាមទារឯកសារដើមពេញមួយសប្តាហ៍ ដោយធ្វើឲ្យមានការជជែកតវ៉ាជាច្រើនពីភាគីផ្សេងទៀតក្នុងបន្ទប់សវនាការ។ ការទទូចម្តងហើយម្តងទៀតរបស់លោក **នួន ជា** បានធ្វើឲ្យចៅក្រមនៃអង្គជំនុំជម្រះខឹងសម្បា ហើយនៅចុងសប្តាហ៍ចៅក្រមបានកាត់សេចក្តីថា ការបដិសេធមិនឆ្លើយតបនឹងឯកសារថតចម្លងរបស់ជនជាប់ចោទ គឺមានន័យថាជនជាប់ចោទបានអនុវត្តសិទ្ធិរក្សាភាពស្ងៀមស្ងាត់ តែទោះបីជាមេធាវីការពារក្តីលោក **នួន ជា** បានតវ៉ាថា កូនក្តីខ្លួនបានព្យាយាមឲ្យមានដំណោះស្រាយស្តីពីយថាភាពនៃឯកសារដែលដាក់បង្ហាញចំពោះមុខគាត់ ដែលផ្ទុយពីការអនុវត្តន៍សិទ្ធិដូចចៅក្រមបានលើកឡើង ។

លោក **ខៀវ សំផន** បានបន្តអនុវត្តសិទ្ធិរបស់គាត់នៅស្ងៀមស្ងាត់មិនឆ្លើយតបនឹងសំណួរនៅសប្តាហ៍នេះ។ អង្គជំនុំជំម្រះ បានសួរគាត់ម្តងហើយម្តងទៀត ឲ្យជនជាប់ចោទរូបនេះផ្តល់ការអត្ថាធិប្បាយលើសម្រង់ខ្លីៗចេញពីឯកសារក្នុងសំណុំរឿង ក៏ប៉ុន្តែលោក **ខៀវ សំផន** បានបញ្ជាក់យ៉ាងច្បាស់លាស់ថា គាត់មិនមានបំណងចង់ឆ្លើយតបទៅនឹងសំណួរទាញចេញពីសម្រង់ទាំងនោះឡើយ ។ ការទទូចទាមទារឲ្យមានការឆ្លើយតបរបស់លោក **ខៀវ សំផន** ពីសំណាក់អង្គជំនុំជម្រះទាំងគាត់មិនចង់ឆ្លើយដូច្នេះ បាននាំឲ្យមានការប្រទាញប្រទង់គ្នាយ៉ាងតឹងតែងជាច្រើនលើកច្រើនសាពីសំណាក់មេធាវីការពារក្តីរបស់គាត់ ទោះបីជាការខិតខំនេះ មិនបានសម្រេចក៏ដោយ។

## *ជំពូកទី២ ៖* សេចក្តីសង្ខេបសក្ខីកម្ម

ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបសក្ខីកម្មរបស់ជនជាប់ចោទលោក **នួន ជា** សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីលោក **រ៉េម យន** និងលោក **ភ្លាន ហ៊ឺត**។

### ក. សក្ខីកម្មរបស់លោក នួន ជា

សវនាការនៅសប្តាហ៍នេះ សហព្រះរាជអាជ្ញា បានសួរដេញដោលលោក **នួន ជា** អំពីប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា។ ផ្នែកដំបូងនៃការតាំងសំណួររបស់សហព្រះរាជាអាជ្ញា គឺសំដៅការបោះពុម្ពផ្សព្វផ្សាយ*ទស្សនាវដ្តីទង់បដិវត្តន៍* របស់ខ្មែរក្រហម។ បន្ទាប់មក សហព្រះរាជអាជ្ញាបានសួរពីដំណាក់កាលទាំងបួនសំខាន់ៗដូចជាប្រវត្តិសាវតារបក្សកុម្មុយនីស្តកម្ពុជាពីឆ្នាំ ១៩៦០ ដល់ឆ្នាំ១៩៧៥។ ដំណាក់កាលទី១ គឺការកើតចេញពីសមាជបក្សកុម្មុយនីស្តកម្ពុជាឆ្នាំ១៩៦០ ដែលរួមមានទាំងការតែងតាំងសមាជិកភាពបក្ស និងមាគ៌ាបក្សកុម្មុយនីស្ត

កម្ពុជា។ ដំណាក់កាលទី២ ទាក់ទងនឹងការធ្វើសមាជបក្សកុម្មុយនីស្តកម្ពុជា ឆ្នាំ១៩៦៣។ ដំណាក់កាលទី៣ ទាក់ទងទៅនឹងប្រតិបត្តិការនៃ ***មន្ទីរ ១០០*** ក្នុងអំឡុងឆ្នាំ១៩៦៣ រហូតទៅដល់ការធ្វើរដ្ឋប្រហាររបស់ **លន់ នល់** កាលពីឆ្នាំ១៩៧០។ ដំណាក់កាលទី៤ ទាក់ទងនឹងឆ្នាំ១៩៧០ រហូតដល់ ***ថ្ងៃរំដោះ*** ខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលខ្មែរក្រហមបានគ្រប់គ្រងលើក្រុងភ្នំពេញទាំងស្រុង។

### *ក.១. ទង់បដិវត្តន៍*

សវនាការនៅក្នុងសប្តាហ៍នេះ បានចាប់ផ្តើមដំបូងដោយភាគីសហព្រះរាជអាជ្ញាបានតាំងសំណួរទៅកាន់លោក **នួន ជា** ដើម្បីឲ្យគាត់បកស្រាយពីបញ្ហាទាក់ទងនឹងការបោះពុម្ពផ្សព្វផ្សាយ *ទស្សនាវដ្តីទង់បដិវត្តន៍* ដោយបញ្ជាក់ឡើងវិញនូវអ្វីដែលចៅក្រម **ស៊ីលវៀ ខាតរ៉ាយថ៍** *(Judge Silvia CARTWRIGHT)* បានសួរជនជាប់ចោទ **នួន ជា** នូវប្រធានបទដូចគ្នានេះកាលពីខែធ្នូ ឆ្នាំ២០១១។ យោងទៅតាមលោក **នួន ជា** ទស្សនាវដ្តីទង់បដិវត្តន៍បានបង្កើតឡើងតាំងពីមុនពេលមានកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវឆ្នាំ១៩៥៤ មកម្ល៉េះ មិនមែនក្នុងអំឡុងពេលធ្វើសមាជបក្សកុម្មុយនីស្តកម្ពុជាកាលពីឆ្នាំ១៩៦០ នោះទេ។ លោក **នួន ជា** បានពន្យល់ថាគណៈអចិន្ត្រៃយ៍បានបង្កើតទង់បដិវត្តន៍ជាទស្សនាវដ្តីសរសេរដោយដៃដោយសារពេលនោះ ស្ថានភាពនៅក្នុងតំណ្ឌចិនមានភាពច្របូកច្របល់ច្រើន បន្ទាប់ពីមានកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវហើយ។ ទង់បដិវត្តន៍ ត្រូវបានធ្វើឡើងដោយការសរសេរដោយដៃលើក្រដាសក្រមួន ហើយបក្សបានរៀបចំបោះពុម្ពចែកចាយមុនពេលរបបកម្ពុជាប្រជាធិបតេយ្យចេញជារូបរាងពិតប្រាកដឡើង។ យោងតាមជនជាប់ចោទ **នួន ជា** ការបោះពុម្ពផ្សាយក្រោយៗមកទៀតរបស់ទង់បដិវត្តន៍ត្រូវបានប្តូរឈ្មោះ ហើយចុះផ្សាយជាអក្សរពុម្ពក្រោយពីការរំដោះក្នុងឆ្នាំ១៩៧៥ ហើយខណៈដែលពេលនោះខ្មែរក្រហមអាចមានលទ្ធភាពរៀបចំឲ្យមានដំណើរការរោងពុម្ពបាន ។ លោក **នួន ជា** បានផ្តល់សក្ខីកម្មថា ពីមុនទង់បដិវត្តន៍មានរូបភាពទង់ជាតិពណ៌សតែមួយទេនៅខាងក្នុងផ្ទៃក្រហមទាំងមូល តែមានការកែទម្រង់ក្រោយមកទៀត ដោយបានប្តូរទៅជាទង់ជ័យពណ៌ក្រហមមួយដែលមានទង់តូចៗពណ៌សចំនួន៥។ ភាគីសហព្រះរាជអាជ្ញាបានស្វះស្វែងធ្វើយ៉ាងណា ដើម្បីរកភស្តុតាងដាក់បន្ទុកលើជនជាប់ចោទ តាមរយៈការលើកឡើងនូវប្រធានបទទាក់ទងទៅនឹងគោលនយោបាយរបស់ខ្មែរក្រហមដោយសួរជនជាប់ចោទឲ្យឆ្លើយបញ្ជាក់ ឬផ្តល់មតិយោបល់ចំពោះសម្រង់ខ្លឹមសារផ្សេងៗគ្នាដែលមានចែងនៅក្នុងទង់បដិវត្តន៍។ មានការផ្តោះផ្តងដ៏គួរឲ្យចាប់អារម្មណ៍មួយបានឡើង នៅពេលដែលសហព្រះរាជអាជ្ញាអន្តរជាតិ លោក **ឌេល លីសាក់** *(Dale LYSAK)* បានដកស្រង់ពីភាពខ្វែងគំនិតគ្នា ដែលមានរៀបរាប់ជាហូរហែក្នុងទស្សនាវដ្តីទង់បដិវត្តន៍ ហើយមានឃ្លាឃ្លោងខ្លះដែលតាមព្រះរាជអាជ្ញាថា លោក **នួន ជា** ក៏បានថ្លែងនៅក្នុងសេចក្តីផ្តើមរបស់វាផងដែរ។ ជាការឆ្លើយតប លោក **នួន ជា** បានធ្វើការបកស្រាយពីភាពខុសគ្នារវាងពាក្យថា "ជំទាស់បដិបក្ខ" និង "ទំនាស់ផ្ទៃក្នុង"។ គាត់បានបកស្រាយថា ជំទាស់បដិបក្ខ គឺជាទំនាស់រវាងពួកឈ្លានពានវាតទីនិយម ជាទំនាស់ជាមួយនឹងប្រទេសខាងក្រៅដែលឈ្លានពានមកលើទឹកដីនៃប្រទេសកម្ពុជា ដែលទំនាស់នេះគឺជាបញ្ហាអាយុជីវិត ឬជាទំនាស់ស្លាប់រស់។ រីឯទំនាស់ផ្ទៃក្នុងវិញ គឺជាទំនាស់រវាងកសិករ និងម្ចាស់ដី ដែលទំនាស់ប្រភេទនេះអាចដោះស្រាយបានដោយការប្រជុំ "ការរៀនសូត្រ"

ការពិភាក្សាគ្នាជាមូលដ្ឋាន ការចរចាគ្នា ការរកហេតុផលថាតើមូលហេតុនៃទំនាស់នោះកើតចេញពីអ្វី។ ព្រះរាជអាជ្ញាបានដកស្រង់ឃ្លាខ្លះៗពីទង់បដិវត្តន៍ ដើម្បីប្រឆាំងទៅនឹងការបកស្រាយរបស់លោក **នួន ជា** ចំពោះការបកស្រាយពីទំនាស់ផ្ទៃក្នុងដោយបានបន្ថែមថា ការពិតទំនាស់ប្រភេទនេះក៏មានបញ្ចូលនូវការតស៊ូស្លាប់រស់រវាងវណ្ណៈផ្សេងៗគ្នានៅក្នុងសង្គមខ្មែរផងដែរ។ បើទោះណាជាពីដំបូងទី លោក **នួន ជា** បានបដិសេធមិនព្រមឆ្លើយតបនូវការដកស្រង់ខ្លឹមសារ ឬឃ្លាឃ្លោងពីឯកសារអេឡិចត្រូនិច ដើម្បីមកធ្វើការតាំងសំណួរដេញដោលលើរូបគាត់ក្នុងបន្ទប់សវនាការក្តី តែនៅទីបំផុតគាត់ស្រាប់តែបានឆ្លើយតបទៅនឹងសំណួររបស់ភាគីសហព្រះរាជអាជ្ញាលើបញ្ហានេះ។ លោក **នួន ជា** បានច្រានចោលនូវការលើកឡើងថាទំនាស់ផ្ទៃក្នុងរវាងវណ្ណៈ និងវណ្ណៈ ដែលកើតមានក្នុងសង្គមខ្មែរ គឺមានន័យដូចគ្នាទៅនឹងទំនាស់បដិបក្ខជាមួយប្រទេសខាងក្រៅដែរ។ យោងតាមលោក **នួន ជា** បានឲ្យដឹងថា វាមិនអាចជាការពិតទៅកើតទេចំពោះការលើកហេតុផលថា ទំនាស់រវាងម្ចាស់ដី និងកសិករ គឺជាបញ្ហាស្លាប់រស់នៅក្នុងមនោគមវិជ្ជាខ្មែរក្រហម តែផ្ទុយទៅវិញបក្សចង់សំដៅទៅលើ "ម្ចាស់ដីឃោរឃៅ" ជាម្ចាស់ដីដែលជា "បរិវារឲ្យបរទេស"បម្រើផលប្រយោជន៍ឲ្យពួកឈ្លានពានទឹកដីនៃប្រទេសទាំងមូលតែប៉ុណ្ណោះ ដែលនាំឲ្យក្លាយទៅជាទំនាស់បដិបក្ខស្លាប់រស់ ។ លោក **នួន ជា** បានបន្ទោសសហព្រះរាជអាជ្ញាក្នុងការដែលច្បិចយកតែចំណុចខ្លីៗ ឬមួយកំណាត់មួយមកសួរនាំគាត់ ដែលខុសពីឯកសារសម្អាងនោះ មានការអត្ថាធិប្បាយជាហូរហែឲ្យយល់ស៊ីជម្រៅចំពោះបញ្ហានេះ ។

សហព្រះរាជអាជ្ញា បានចោទសួរបន្ថែមទៀតអំពីសំណួរដែលទាក់ទងនឹងការបែងចែកតំបន់ ឬទីក្រុងទីប្រជុំជន រួមទាំងមនោគមវិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា ចំពោះការដែលបានចាត់ទុកវណ្ណៈនៃក្រុមមនុស្សជាក់លាក់មួយចំនួនជាសត្រូវរបស់បក្ស។ លោក **នួន ជា** បានទទួលស្គាល់ថា បក្សពិតជាបានយកទីចុងកាត់មាត់ញកជាចំណុចចាប់ផ្តើមសំខាន់ក្នុងផែនការអភិវឌ្ឍន៍របស់ខ្លួន ដោយសារស្ថានភាពជាក់ស្តែង ដែលបានកើតឡើងក្នុងគ្រានោះ និងក៏ពីព្រោះតែបក្សជឿជាក់ថា អ្នកជនបទមានជីវភាពក្រីក្រលំបាកតោកយ៉ាកជាងនៅទីក្រុង។ គាត់បានពន្យល់ថា អ្នកនៅជនបទត្រូវតែទទួលបានការយកចិត្តទុកដាក់ដោយសារភាពក្រីក្រ ពួកគេមិនអាចមានអាហារបរិភោគគ្រប់គ្រាន់ និងសំលៀកបំពាក់បានសមរម្យ ដែលផ្ទុយពីអ្នកទីក្រុងដែលមានស្ថានភាពរស់នៅសមរម្យជាង ។ ជាគោលការណ៍ បក្សបានបំផុសអ្នកក្រីក្រទាំងនោះឲ្យមានការភ្ញាក់រឭកដាំដុះបន្លែបង្ការ និងធ្វើការកែប្រែជីវភាពរបស់ពួកគេពីទីជនបទមកមុន ព្រោះអ្នកទីក្រុងអាចមានល្មមហូបហើយ ប៉ុន្តែក៏មិនមែនមានន័យថាបក្សបានចងគំនុំជាមួយនឹងវណ្ណៈនានាក្នុងទីក្រុងឡើយ។

យោងតាមលោក **នួន ជា** បក្សកុម្មុយនីស្តកម្ពុជា បានយកការដោះស្រាយផ្អែកតាមស្ថានភាពជាក់ស្តែង និងបានធ្វើការអប់រំ ក៏ដូចជាជំរុញឲ្យអ្នកក្រព្យាយាមកែប្រែជីវភាពរស់នៅបានសមរម្យជាងមុន។ អ្វីដែលសំខាន់នោះលោក **នួន ជា** ក៏បានថ្លែងថា អ្នកនៅជនបទ គឺបានទទួលរងនូវការលំបាកខ្លាំង ហើយត្រូវបានគេ (ម្ចាស់ដីអ្នកមាន) ធ្វើបាបជាប្រចាំ ។

លោក **នួន ជា** បានទាមទារសាជាថ្មីសុំមើលឯកសារដើមរបស់ទស្សនាវដ្ដីទង់បដិវត្តន៍ និងទង់ក្រហម ដែលភាគីសហព្រះរាជអាជ្ញាបានដកស្រង់ធ្វើការតាំងសំណួរមកលើរូបគាត់ ដែលទង្វើនេះបាបនាំឲ្យកើតមានការជជែកវែកញែកនូវបញ្ហាស្ដីពីយថាភាព និងការជឿជាក់បាននៃឯកសារនៅសប្ដាហ៍នេះ។ នៅជំពូកទី៤ នៃរបាយការណ៍នេះ នឹងផ្ដល់នូវការវិភាគលម្អិតដោយគ្របដណ្ដប់លើបញ្ហាផ្លូវច្បាប់ និងនីតិវិធីចំពោះអ្វីដែលតុលាការបានប្រឈម ។

### *ក.២. មហាសន្និបាទលើកទី១ របស់បក្សកុម្មុយនីស្តកម្ពុជា ឆ្នាំ១៩៦០*

ភាគីសហព្រះរាជអាជ្ញាបន្ដសួរលោក **នួន ជា** ទាក់ទងនឹងការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាស្ដីពីៈថាតើនរណាជាអ្នកដឹកនាំ អ្នកទាំងនោះតែងតាំងដោយរបៀបណា ហើយបុគ្គលណាដែលបានដឹកនាំការធ្វើសមាជបក្សកុម្មុយនីស្តកម្ពុជានៅក្នុងឆ្នាំ១៩៦០។ បន្ទាប់មក សហព្រះរាជអាជ្ញា បានសួរជនជាប់ចោទរូបនេះ អំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាស្ដីពីការបោះពុម្ពផ្សាយទស្សនាវដ្ដីទង់បដិវត្តន៍។ នៅអំឡុងពេលនៃការធ្វើសមាជនេះហើយដែលមាគ៌ាបក្សដំបូងរបស់បក្សត្រូវបានអនុម័តឡើង។ ហើយចាប់ពីពេលនោះមក ក៏លែងមានការទទួលស្គាល់ឈ្មោះចាស់របស់បក្សគឺ “បក្សពលករកម្ពុជា” ។

#### *ក.២.ក ការតែងតាំងគណៈដឹកនាំបក្ស និងលេខាតំបន់*

យោងតាមការផ្ដល់សក្ខីកម្មដែលបានផ្ដល់ដោយលោក **នួន ជា** បានឲ្យដឹងថា តា **ទូ សាមុត សាឡុត ស** ហៅ **ប៉ុល ពត** បង **ម៉ី ម៉ាន** និង **ស៊ីវ ហេង** ជាអ្នកដឹកនាំបក្សកុម្មុយនីស្តកម្ពុជា។ ភាគច្រើននៃអ្នកដឹកនាំបក្សបានសម្រេចតែងតាំងលោក **ទូ សាមុត** ជាអ្នកដឹកនាំ និងជាលេខាបក្សគណៈអចិន្ត្រៃយ៍។ ជនជាប់ចោទបានបំភ្លឺថា គាត់ផ្ទាល់នាពេលនោះ គឺជាអនុលេខាបក្សនៃគណៈអចិន្ត្រៃយ៍ ទទួលបន្ទុកផ្នែកអប់រំនិងទំនាក់ទំនងជាមួយវៀតណាម។ ផ្អែកតាមលោក **នួន ជា** គាត់ក៏ជាអ្នកទទួលខុសត្រូវនៅក្នុងការក្ដាប់សភាពការណ៍នៅជនបទ រីឯលោក **ប៉ុល ពត** និង **ម៉ី ម៉ាន** ជាអ្នកមាននាទីក្ដាប់សភាពការណ៍នៅទីក្រុង។ បន្ថែមពីនេះទៀត **សាឡុត ស** ជាអ្នកទទួលខុសត្រូវជាមួយក្រុមបញ្ញាជន។ លោក **នួន ជា** បានរៀបរាប់ទៀតថា **សាឡុត ស** និង **ទូ សាមុត** ទទួលខុសត្រូវខាងជ្រើសរើសសមាជិក ដែលមកពីខាងកើត ខាងលិច និងខាងជើង។ សមមិត្ត **កែវ មាស** និង **តាម៉ុក** បានក្លាយជាសមាជិកគណៈមជ្ឈិមក្នុងឆ្នាំ១៩៦០ និងឆ្នាំ១៩៦៣។ បន្ទាប់មក សមមិត្ត **វន វ៉េត** ជំនួសឲ្យសមមិត្ត **កែវ មាស** នៅពេលដែលបក្សបានឈ្វេងយល់ថា សមមិត្ត **កែវ មាស** លែងជាបុគ្គលដែលមិនអាចទុកចិត្តតទៅទៀតបាន ។ លោក **នួន ជា** បន្ថែមទៀតថា លោក **អៀង សារី** និង **សុន សេន** ក៏ជាសមាជិកគណៈអចិន្ត្រៃយ៍ដែរ ហើយ **សោ ភឹម** កាលណោះ ជាលេខាតំបន់ទិសបូព៌ា។ ជនជាប់ចោទបានថ្លែងថា ភូមិភាគនីមួយៗបានចាត់ចែងតែងតាំងលេខាភូមិភាគរៀងៗខ្លួន រីឯអ្នកដែលត្រូវបានគេជ្រើសចាត់តាំងនោះ ត្រូវបានបង្ហាញខ្លួនតំណាងឲ្យភូមិភាគរបស់គេនៅក្នុងសមាជបក្សឆ្នាំ ១៩៦០ ។ មានប្រាំមួយទៅប្រាំពីររូបនៃលេខាធិការភូមិភាគដែលត្រូវបានតែងតាំងហើយជាស្រេច ព្រមទាំងមានសមាសភាពដែលធ្លាប់នៅក្នុងចលនាតស៊ូប្រឆាំងនឹងបារាំង និងថ្នាក់ដឹក

នាំខ្មែរផ្សេងទៀតប្រចាំភូមិភាគមួយចំនួនផ្សេងទៀត ក៏ត្រូវបានចូលរួមនៅក្នុងសមាជបក្សដំបូងនេះដែរ ។ លោក **នួន ជា** បានអះអាងថា សមាជនេះ បានរួមបញ្ចូលទាំងចំណាត់ការនៃការជ្រើសតាំងបេក្ខជនជាលេខាភូមិភាគនីមួយៗជាសំខាន់ ។

## *ក.២.ខ ការណែនាំពីមាគ៌ាបក្ស នៅមហាសន្និបាតឆ្នាំ១៩៦០*

សហព្រះរាជអាជ្ញា **លីសាក់** បានចោទសួរទៅកាន់លោក **នួន ជា** ពីបញ្ហាមាគ៌ាបក្សកុម្មុយនីស្តកម្ពុជានៅក្នុងការកំណត់នូវប្រភេទសត្រូវ ដោយសហព្រះរាជអាជ្ញាបានយោងលើប្រតិចារិកដែលបានពីមហាសន្និបាតឆ្នាំ១៩៦០។ ប្រតិចារិកបានបង្ហាញថា សត្រូវមានពីរប្រភេទ ទី១ "ចក្រពត្តិនិយម ពិសេសអាមេរិកាំង" ហើយសត្រូវទី២ គឺវណ្ណៈសក្តិភូមិដែលរួមមានម្ចាស់ដី និងពួកប្រតិកិរិយា។ លោក **នួន ជា** បានរក្សាជំហរថា បក្សកុម្មុយនីស្តកម្ពុជាបានកំណត់សត្រូវផ្អែកលើរបបនៃការគ្រប់គ្រង មិនមែនលើវណ្ណៈ ឬក៏ប្រជាជននៃវណ្ណៈណាមួយនោះទេ។ ជាដំបូងលោក **នួន ជា** បានពន្យល់ថា ឯកសារដែលលោក **លីសាក់** បានលើកឡើង គឺមិនត្រឹមត្រូវទេ ហើយបន្ទាប់មក គាត់បានបកស្រាយយ៉ាងដូច្នេះថា៖ សត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា គឺជាពួកបរិវារចក្រពត្តិឈ្លានពានដែលជាជនក្បត់ជាតិរបស់ខ្លួន ហើយគាំទ្រភាគីចក្រពត្តិនិយមឲ្យចូលឈ្លានពានកម្ពុជា សត្រូវមួយទៀត គឺពួកសក្តិភូមិដែលក្រុមបុគ្គលនេះ គឺសំដៅលើម្ចាស់ដីឃោរឃៅយង់ឃ្នង និងពួកប្រតិកិរិយា។ លោក **នួន ជា** បាននិយាយគូសបញ្ជាក់ថា មិនមែនគ្រប់ម្ចាស់ដីសុទ្ធតែត្រូវបានចាត់ទុកថាជាសក្តិភូមិទេ។ នៅពេលលោក **លីសាក់** បានសង្កត់ធ្ងន់ថាតើបក្សកុម្មុយនីស្តកម្ពុជាក៏បានចាត់ទុកពួកអភិជន ឬកពួកអាណិកជនអារីស្តូក្រាដដែលរួមមានដូចជាស្តេច មន្ត្រីជាន់ខ្ពស់ ថៅហ្វាយស្រុក ជាសត្រូវរបស់បក្សដែរ ឬយ៉ាងណា? ចំណុចនេះលោក **នួន ជា** បានប្រកែកដាច់អហង្ការ និងបានថ្លែងថា ពួកអភិជនអារីស្តូក្រាដខ្លះក៏មានអ្នកស្នេហាជាតិដែរ អ៊ីចឹងហើយមិនអាចម៉ៅបានទាំងអស់ថាអ្នកទាំងនោះជាសត្រូវទេ។ លោក **នួន ជា** បានបន្ថែមទៀតថា បក្សកុម្មុយនីសកម្ពុជាមិនមែនចេះតែចាត់ទុកថា បុគ្គលមកពីក្រុមនេះក៏សត្រូវ ក្រុមនោះក៏សត្រូវដូចដែលសហព្រះរាជអាជ្ញាបានលើកឡើងនោះទេ ហើយថែមទាំងបានដាស់តឿនសហព្រះរាជអាជ្ញាកុំឲ្យថ្លែងនូវបញ្ហាទាំងនេះងាយៗពេក។ ផ្ទុយទៅវិញ ជនជាប់ចោទ បានប្រាប់តុលាការថា សត្រូវអាចជាបុគ្គល ជាក្រុមពួកដែលបំផ្លាញជាតិ និងពួកចារកម្ម ជាក្រុមដែលធ្វើការផ្តល់ដំណឹងឲ្យទៅខ្មាំង ។ យ៉ាងណាមិញ ការចាត់ទុកថានណាម្នាក់ជាសត្រូវ គឺបក្សមានគោលការណ៍ច្បាស់លាស់ មិនមែនគ្រប់បុគ្គលទាំងអស់ចាត់ទុកថាជាសត្រូវឡើយ បើមិនអញ្ចឹងទេប្រទេសកម្ពុជាប្រហែលត្រូវបានបែកបាក់ខ្ចាត់ខ្ចាយអស់ហើយ។ លោក **នួន ជា** បានបន្ថែមទៀតថា គោលការណ៍របស់បក្សកុម្មុយនីស្តកម្ពុជានាពេលនោះ គឺដូចមានចែងក្នុងពាក្យស្លោកថា "កាត់បន្ថយសត្រូវ បន្ថែមមិត្តជាអិបរមា"។

ប្រសិនបើអ្វីដែលលោក **នួន ជា** បានថ្លែងកន្លងមកគួរឲ្យជឿជាក់បាននោះ មានន័យថា មាគ៌ាបក្សដែលធ្វើឡើងនៅមហាសន្និបាតឆ្នាំ១៩៦០ អាចនឹងត្រូវបានធ្វើវិសោធនកម្មបាន លុះត្រាតែមានការចូលរួមពីសមាជិកទាំងអស់ពីគ្រប់ទីកន្លែងទូទាំងប្រទេស។ ដូចនេះគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមមិនមានអំណាចដាច់ខាតក្នុងការកែប្រែមាគ៌ាបក្សនោះទេ។ លោក **នួន ជា** បានបដិសេធថា គាត់មិនចាំថាតើមានការកែប្រែមាគ៌ាបក្សដែរ ឬទេ

រវាងមាគ៌ាបក្សដែលបានអនុម័តកាលពីឆ្នាំ១៩៦០ និង១៩៧៥ (បន្ទាប់ពីបានរំដោះហើយ)។ លោក **នួន ជា** បានបដិសេធនៅពេលលោកត្រូវបានសួរថា តើលោកទទួលតួនាទីជានាយករដ្ឋមន្ត្រីស្តីទី ជំនួស **ប៉ុល ពត** ខណៈដែលមានពេលមួយនោះ **ប៉ុល ពត** ធ្លាក់ខ្លួនឈឺ? លោក **នួន ជា** បានឆ្លើយតបថា ទោះបីជាលោក **ប៉ុល ពត** ឈឺអស់រយៈពេលច្រើនខែក្តី ក៏ប៉ុន្តែទាំងរូបគាត់ផ្ទាល់ទាំងលោក **ខៀវ សំផន** មិនបានបំពេញតួនាទីជំនួសលោក **ប៉ុល ពត** ឡើយ។ លោក **នួន ជា** បានថ្លែងថា ពួកគាត់មិនអាចជំនួសតំណែងរបស់លោក **ប៉ុល ពត** បានទេដោយហេតុថា ពួកគាត់មិនមានបន្ទុកទទួលខុសត្រូវផ្នែកយោធា និងបានបញ្ជាក់ថា **សុន សេន** ពេលនោះ គឺជាអ្នកជំនួសមុខងារបណ្តោះអាសន្ន នៅពេលដែលលោក **ប៉ុល ពត** ឈឺ។

ទាក់ទងនឹងការបង្កើតកងការពារសម្ងាត់វិញលោក **នួន ជា** បានស្រាយបំភ្លឺថាកងការពារនេះមិនទាន់ត្រូវបានបង្កើតឡើងនៅឡើយទេកាលពីមុនមហាសន្និបាតឆ្នាំ១៩៦០។ ក្រុមកងការពារសម្ងាត់ទាំងនោះ ត្រូវបានបង្កើតឡើងដើម្បីតាមការពារកម្មាភិបាល។ សមាជិកកងការពារ ជាកូនចៅរបស់កម្មាភិបាល ហើយក៏មានប្រភពជាកសិករផងដែរ។ លោក **នួន ជា** ក៏បានបដិសេធផងដែរថា ចំពោះពាក្យដែលបានប្រើដោយសហព្រះរាជអាជ្ញាថា កងការពារសម្ងាត់ទាំងនេះ ជាយោធាកុមារដោយគាត់បានសម្អាងថា ថ្វីត្បិតតែកុមារទាំងនេះមានអាយុ១៥ ឬ១៦ឆ្នាំពិតមែន តែពួកគេគ្មានអាវុធទេ មានតែដំបង និងកាំបិតដើម្បីដាក់ជាប់ខ្លួននៅពេលត្រូវបំពេញការងារ។ លើសពីនេះទៀត លោក **នួន ជា** បានបន្តពន្យល់ថា កងការពារសម្ងាត់ទាំងនេះ មិនមែនត្រូវបានចាត់តាំងឲ្យក្លាយជាយោធាតស៊ូប្រដាប់អាវុធឡើយ ដោយសារតែបក្សពេលនោះមិនទាន់មានអាវុធផង ក៏ប៉ុន្តែការបង្កើតក្រុមនេះឡើង គឺគ្រាន់តែជាផ្នែកមួយនៃការតស៊ូនយោបាយបដិវត្តន៍របស់បក្សតែប៉ុណ្ណោះ។ អ្វីដែលចាប់អារម្មណ៍នោះលោក **លីសាក់** បានសួរទៅកាន់លោក **នួន ជា** អំពីវិសាលភាពនៃអំណាចរបស់កងការពារសម្ងាត់ក្នុងការ "កំចាត់ខ្មាំងអ្នកដែលជ្រៀតជ្រែកនយោបាយបក្ស"[1] ថាតើបក្សបានចាត់ការដូចម្តេចចំពោះបុគ្គលទាំងឡាយណាដែលត្រូវបានរកឃើញថាជាខ្មាំង? ចំណុចនេះ លោក **នួន ជា** ហាក់បីដូចជាមិនចាំពីពេលវេលាជាក់លាក់នៅពេលដែលរឿងរ៉ាវនេះបានកើតឡើងនោះទេ។ ជំនួសឲ្យការឆ្លើយតបទៅនឹងព្រឹត្តិការណ៍នានាក្នុងអំឡុងឆ្នាំ១៩៦០ លោក **នួន ជា** បែរជាឆ្លើយតបពីបរិបទដែលកើតឡើងបន្ទាប់ពីខែមេសា ឆ្នាំ១៩៧៥ទៅវិញ។ គាត់បានពន្យល់ថា ខ្មាំងដែលត្រូវបានចាប់នោះ ត្រូវបានស៊ើបអង្កេតអស់រយៈពេលមួយ ឬពីរឆ្នាំមុនពួកគេត្រូវបានចាប់ខ្លួន ហើយបញ្ជូនទៅមន្ទីរសន្តិសុខ (ស-២១) ជាទីកន្លែងដែលអ្នកទាំងនោះត្រូវបានសួរចម្លើយ និងបានទទួលនូវចម្លើយសារភាពបន្ថែម។

### *ក.៣. ការធ្វើមហាសន្និបាតបក្សលើកទី២ ក្នុងឆ្នាំ១៩៦៣*

លោក **នួន ជា** បានចងចាំថា មានមនុស្សម្នាជាច្រើនបានចូលរួមមហាសន្និបាតបក្សលើកទី២ ដែលត្រូវបានធ្វើឡើងក្នុងឆ្នាំ១៩៦៣។ គាត់បានថ្លែងថា លក្ខណៈវិនិច្ឆ័យដើម្បីជ្រើសរើសបុគ្គលណាម្នាក់ជាលេខាបក្ស គឺ

អាស្រ័យទៅលើគុណសម្បត្តិក្នុងកសាងបដិវត្តន៍ (គាត់មិនបានពន្យល់ថា វាមានន័យស៊ីជម្រៅដូចម្តេចនោះទេ) ពួកគេត្រូវមានសមត្ថភាពដឹកនាំ មានមហាជននិយមគាំទ្រ អាយុ និងមានភាពចាស់ទុំ។ យោងតាមលោក **នួន ជា** បានឲ្យដឹងថា ការប្រជុំមហាសន្និបាតលើកទី២ **ប៉ុល ពត** ត្រូវបានគេគាំទ្រ និងជ្រើសតាំងឲ្យក្លាយជាលេខាបក្ស ព្រោះតែ **ប៉ុល ពត** មានសមត្ថភាពអាចបំពេញការងារ ត្រូវតាមជំនាញច្រើនជាងរូបគាត់។ ដូចនេះ លោក **នួន ជា** នៅតែជាអនុលេខាបក្ស។ ទាក់ទងទៅនឹងការជ្រើសតាំងសមាជិកគណៈអចិន្ត្រៃយ៍វិញ លោក **នួន ជា** បានធ្វើការអះអាងថា អាចចាំបានមានដូចជាលោក **ប៉ុល ពត** ជាលេខាបក្ស ខ្លួនគាត់ផ្ទាល់ជាអនុលេខាបក្ស លោក **អៀង សារី** លោក **សោ ភឹម** និង **តាម៉ុក** អ្នកផ្សេងពីនេះ គាត់មិនអាចចាំបានអស់ទេ។ លោក **នួន ជា** បានបន្ថែមទៀតថា ក្រៅពីគោលបំណងសំខាន់នៃការធ្វើសមាជ គឺដើម្បីជ្រើសតាំងសមាជិកមជ្ឈិម និងសមាជិកអចិន្ត្រៃយ៍ មហាសន្និបាតមួយនេះក៏បានប្តូរឈ្មោះបក្សពី "បក្សពលករ" ទៅជា "បក្សកុម្មុយនីស្តកម្ពុជា" ផងដែរ។

### *ក.៤. ព្រឹត្តិការណ៍អំឡុងឆ្នាំ១៩៦៣ និងឆ្នាំ១៩៧០*

យោងតាមសក្ខីកម្មរបស់លោក **នួន ជា** រវាងឆ្នាំ១៩៦៣ ទៅ១៩៧០ លោក **ប៉ុល ពត** លោក **អៀង សារី** ហើយនិងលោក **សុន សេន** បានសម្រេចផ្លាស់ប្តូរទីស្នាក់ការបក្ស និងមន្ទីរគណៈមជ្ឈិមហៅថា *មន្ទីរ១០០* ដែលធ្លាប់តែមានទីតាំងនៅក្បែរព្រំដែនប្រទេសកម្ពុជាវៀតណាម ទៅនៅទីតាំងថ្មីនៅខេត្តរតនគិរីវិញ។ ខេត្តនេះ ស្ថិតនៅទិសឦសាននៃប្រទេស ដែលជាទីតាំងដែលបក្សយល់ថា ជាភូមិសាស្ត្រល្អសម្រាប់ដាក់ទីតាំងមូលដ្ឋានបម្រើការងារបដិវត្តន៍ដោយសារវាស្ថិតនៅកណ្តាលព្រៃស្តុក ដែលនឹងនាំឲ្យមានការលំបាកដល់សត្រូវក្នុងការតាមដាន និងជ្រៀតជ្រែកការងារបដិវត្តន៍របស់បក្ស។ នេះគឺជាចំណុចគួរឲ្យចាប់អារម្មណ៍មួយ ព្រោះតែមូលហេតុនៃការមានទីតាំងនៅក្នុងព្រៃស្តុកនេះ បានធ្វើឲ្យគណៈអចិន្ត្រៃយ៍មិនដែលធ្វើការប្រជុំនៅពេលដែល "មន្ទីរ១០០" បានប្តូរទីតាំងថ្មីទៅនៅខេត្តរតនគិរីឡើយ ដោយសារតែវាមានការស្មុគស្មាញពេកក្នុងការធ្វើដំណើរទៅកាន់ទីនោះ។ តាមលោក **នួន ជា** បានឲ្យដឹងថា ការធ្វើដំណើរត្រូវស៊ីពេលប្រហែលមួយខែសម្រាប់ការធ្វើដំណើរទៅកាន់មន្ទីរ ១០០ នៅឯខេត្តរតនគិរី ហើយក៏មិនមានមធ្យោបាយណាអាចធ្វើទៅបាន ក្រៅពីការធ្វើដំណើរដោយថ្មើរជើង។

មានខេត្តមួយចំនួនផ្សេងទៀតដែលស្ថិតក្នុងទិសឦសាននៃប្រទេសផងដែរ រួមមានដូចជា ខេត្តមណ្ឌលគិរី ខេត្តក្រចេះ និងខេត្តស្ទឹងត្រែង។ លោក **នួន ជា** បានទទួលស្គាល់ថា គាត់ពេលនោះ គាត់ជាអ្នកគ្រប់គ្រងនៅភូមិភាគឦសាន និងភូមិភាគនិរតី។ ប៉ុន្តែទោះជាយ៉ាងណា គាត់បានតវ៉ាថា មានលេខាភូមិភាគពីររូបផ្សេងទៀតមានភារៈមើលការគ្រប់គ្រងផ្ទាល់ និងជិតដល់ជាងរូបគាត់។ គាត់បានពន្យល់ថា ក្រោយមកអាចនឹងមានការបន្ថែមភូមិភាគពីរ ឬបីផ្សេងទៀត ប៉ុន្តែគាត់មិនបានចាំថា មានភូមិភាគអ្វីខ្លះឡើយ ហើយក៏មិនដឹងថាបុគ្គលជាក់លាក់ណាជាអ្នកដឹកនាំនៅភូមិភាគទាំងនេះដែរ។ គាត់បានថ្លែងឲ្យដឹងថា ការសម្រេចបន្ថែមភូមិភាគ និងអ្នកដឹកនាំ គឺដើម្បីធានានូវប្រសិទ្ធភាពនៃការដឹកនាំមិនឲ្យបាចសាចទូលំទូលាយពេក។ ផ្អែកតាមលោក **នួន ជា** គណៈ

កម្មការទីក្រុង គឺមានភាពឯករាជ្យម្ចាស់ការពីថ្នាក់ភូមិភាគ ។ គាត់បានផ្តល់សក្ខីកម្មថា លោក **វន វ៉េត** ជាគណៈប្រចាំក្រុងភ្នំពេញ។

នៅពេលដែលសហព្រះរាជអាជ្ញា **លីសាក់** បានតាំងសំណួរ ដោយយោងលើសៀវភៅរបស់លោក **ខៀវ សំផន** ស្តីពីការប្រជុំដែលធ្វើឡើងនៅឆ្នាំ១៩៦៤ និងឆ្នាំ១៩៦៥ លោក **នួន ជា** បានថ្លែងថា គាត់មិនបានចងចាំពីការប្រជុំនោះទេ ប៉ុន្តែគាត់ចាំបាននូវការប្រជុំមួយដែលបានធ្វើឡើងដោយគណៈអចិន្ត្រៃយ៍ កាលពីឆ្នាំ១៩៦៦ ។ នៅក្នុងការប្រជុំនោះ គណៈអចិន្ត្រៃយ៍បានសម្រេចបញ្ចូលនយោបាយបក្ស រួមផ្សំនឹងការតស៊ូអាវុធ។ គាត់បានពន្យល់ថា នៅពេលនោះ ចលនាតស៊ូបដិវត្តន៍មានស្ថានភាពតឹងតែង ហើយទាមទារឲ្យមានការអនុវត្តន៍គោលនយោបាយជាមួយនឹងការប្រើប្រាស់កម្លាំងយោធា។ លោក **នួន ជា** បានរាយរាប់ឈ្មោះបុគ្គលដែលបានចូលរួមការប្រជុំពេលនោះ រួមមានរូបគាត់ផ្ទាល់ **ប៉ុល ពត** និង **សុន សេន** ជាសមាជិកគណៈអចិន្ត្រៃយ៍ បូករួមទាំង កម្មាភិបាលមួយចំនួនទៀតដែលគាត់មិនអាចចាំឈ្មោះបាន។ លោក **នួន ជា** បានគូសបញ្ជាក់ថា ការប្រជុំពេលនោះមិនមានវត្តមានរបស់លោក **អៀង សារី** ទេ ដោយសារគាត់កំពុងបំពេញទស្សនកិច្ចនៅក្រៅប្រទេស។

### *ក.៥. រដ្ឋប្រហាររបស់លោកសេនាប្រមុខ លន់ នល់ ឆ្នាំ១៩៧០ និង ថ្ងៃរំដោះ ១៩៧៥*

លោក **នួន ជា** បានបដិសេធដូច្នេះថា គាត់មិនបានដឹងថាមានកិច្ចខិតខំប្រឹងប្រែងរបស់រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា ក្នុងការព្យាយាមចងសម្ព័ន្ធភាពជាមួយនឹងព្រះមហាក្សត្រ **នរោត្តមសីហនុ** បន្ទាប់ពីព្រះអង្គត្រូវបាន **លន់ នល់** ធ្វើរដ្ឋប្រហារកាលពីខែមីនា ឆ្នាំ១៩៧០។ គាត់បានថ្លែងថា ទាំងនេះ ជាបញ្ហាផ្នែករដ្ឋបាលដែលមិនពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់គាត់ទេ។ ជនជាប់ចោទ ក៏បានអះអាងផងដែរថា គាត់ក៏មិនបានដឹងពីការពាក់ព័ន្ធរបស់លោក **ខៀវ សំផន** នៅក្នុងបញ្ហានេះដែរ ។

សហព្រះរាជអាជ្ញា មានការលំបាកចំពោះបញ្ហានៃការចងចាំរបស់លោក **នួន ជា** ក្នុងការឈ្លេចសួរឲ្យបានព័ត៌មានច្បាស់ការមួយស្តីពីការផ្លាស់ប្តូរមន្ទីរ១០០ ពីខេត្តរតនគិរី ថាតើមន្ទីរនេះបានប្តូរទៅក្បែរស្ទឹងជីនិត ឬនៅក្នុងតំបន់មន្ទីរសន្តិសុខលេខ៧១ ។ លោក **នួន ជា** មិនអាចរម្លឹកការចងចាំ ថាតើគាត់បានជួបលោក **ខៀវ សំផន** នៅស្ទឹងជីនិត កាលពីខែកញ្ញា ឆ្នាំ១៩៧០ ឬអត់ នៅពេលដែលសហព្រះរាជអាជ្ញាសួរគាត់ ដោយបានលើកសម្អាងថាលោក **ខៀវ សំផន** បានផ្តល់នូវអង្គហេតុនេះទៅកាន់ចៅក្រមស៊ើបអង្កេតថាគាត់បានជួប **ប៉ុល ពត** និង **នួន ជា** តាមកាលបរិច្ឆេទខាងលើនេះ។ អ្វីដែលលោក **នួន ជា** អាចចាំបាននោះ គឺថា គាត់ធ្លាប់បានផ្តល់វគ្គអប់រំរៀនសូត្រទៅឲ្យប្រជាជនដែលរស់នៅក្បែរស្ទឹងជីនិត។

លោក **លីសាក់** នៅតែបន្តដីកកកាយចោទសួរនូវព័ត៌មានលម្អិតទាក់ទងនឹងការប្រជុំគណៈមជ្ឈិមនៅវាំងឆ្នាំ១៩៧០ និងខែមេសា ឆ្នាំ១៩៧៥ ។ ជាដំបូង លោក **នួន ជា** បានប្រាប់សហព្រះរាជអាជ្ញាថា គាត់ចាំមិនច្បាស់

មិនដឹងថាតើជាឆ្នាំ១៩៧០ ឬឆ្នាំ១៩៧១ ដែលគណៈមជ្ឈិមធ្វើការប្រជុំសាជាថ្មី។ លោក **នួន ជា** បានថ្លែងថា ការប្រជុំតែងតែមានការផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយ នៅពេលដែលគាត់ត្រូវបានសហព្រះរាជអាជ្ញាសួរគាត់ថាតើមានការប្រជុំគណៈមជ្ឈិមទេក្នុងឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ (ចាំមិនបាន ព្រោះប្រជុំមានច្រើន ហើយទីតាំងប្រជុំតែងតែផ្លាស់ប្តូរជាប្រចាំដើម្បីបំភាន់ដានសត្រូវ)។ បន្ទាប់ពីមានការសួរបញ្ជាក់ជាច្រើនដងពីសំណាក់សហព្រះរាជអាជ្ញា លោក **នួន ជា** បានទទួលស្គាល់ថា គណៈមជ្ឈិមបានរៀបចំការប្រជុំនៅម្តុំស្ទឹងជីនិត បន្ទាប់ពីមន្ទីរនៅខេត្តរតនគិរីត្រូវបានផ្ទេរទៅម្តុំតំបន់នោះ ។

### *ក.៦. ការធ្វើមហាសន្និបាតបក្សលើកទី៣ ក្នុងឆ្នាំ១៩៧១*

លោក **នួន ជា** បានបញ្ជាក់អំពីវត្តមានរបស់គាត់ដែលបានចូលរួមក្នុងមហាសន្និបាតបក្សលើកទី៣ ឆ្នាំ១៩៧១។ ទោះជាយ៉ាងនេះក្តី គាត់ចាំមិនបានទេ ថាតើកន្លែងប្រជុំពេលនោះបានប្រព្រឹត្តនៅទីតាំងណាជាក់លាក់ ហើយក៏មិនបានចាំថា មានការសម្រេចឲ្យបិទទីផ្សារនៅតាមតំបន់រំដោះមួយចំនួនដែរ។

## ខ. សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី រម៉ម យុន

ដើមបណ្តឹងរដ្ឋប្បវេណី លោក **រម៉ម យុន** មកពីខេត្តរតនគិរី ធ្លាប់បានមកផ្តល់សក្ខីកម្មម្តងរួចហើយកាលពីខែធ្នូ ឆ្នាំ២០១១ ហើយដែលពេលនោះ គាត់ត្រូវបានសួរដេញដោលពីសំណាក់ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងភាគីសហព្រះរាជអាជ្ញា។ ដោយសារតែសុខភាពរបស់គាត់មិនអំណោយផល ភ្លាមនោះ អង្គជំនុំជម្រះ ក៏បានសម្រេចឲ្យភាគីទាំងអស់ផ្អាកការសួរដេញដោលលើរូបគាត់ និងបានពន្យារពេលស្តាប់សក្ខីកម្ម រហូតដល់គាត់មានសុខភាពល្អប្រសើរវិញ។ សវនាការសប្តាហ៍នេះ គឺជាការបន្តស្តាប់សក្ខីកម្មរបស់លោក **រម៉ម យុន** ក្រោមការសួរដេញដោលពីសំណាក់ក្រុមមេធាវីការពារក្តី។

ក្នុងពេលសួរដេញដោល លោក **អាង ឧត្តម** មេធាវីជាតិការពារឲ្យលោក **អៀង សារី** បានយោងលើឯកសារមួយចំនួនដើម្បីជួយរម្លឹកការចងចាំរបស់លោក **រម៉ម យុន**។ ដោយមានការអនុញ្ញាតពីអង្គជំនុំជម្រះ ក្រឡាបញ្ជីបានអានឯកសារមួយចំនួនមានដូចជា៖ ផ្នែកមួយនៃលិខិតសួរចម្លើយ និងសេចក្តីថ្លែងការណ៍ធ្វើនៅថ្ងៃ២០ ខែសីហា ឆ្នាំ២០០៨ ដែលលោក **រម៉ម យុន** បានផ្តល់ព័ត៌មានបន្ថែមដល់អង្គភាពគាំពារជនរងគ្រោះ ក្នុងពេលសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ យោងលើឯកសារលោក **រម៉ម យុន** ហៅ **"ខាំភី"** ត្រូវបានចាត់តាំងឲ្យក្លាយជាអនុប្រធានតំបន់ស្រុកវឺនសៃ នៅក្នុងឆ្នាំ១៩៧៨ ជាមួយនឹងសមាជិកប្រាំបួននាក់ទៀត ដែលត្រូវបានតែងតាំងឲ្យមានតួនាទីផ្សេងៗនៅតាមបណ្តាស្រុកដទៃទៀត។ ដើមបណ្តឹងរដ្ឋប្បវេណី **ក្លានហ្វីត** ដែលបានផ្តល់សក្ខីកម្មនៅសប្តាហ៍នេះដែរនោះ ក៏ជាសមាជិកម្នាក់ក្នុងចំណោមប្រាំបួននាក់នោះ ហើយតាមរបាយការណ៍បានឲ្យដឹងថាគាត់ត្រូវបានគេតែងតាំងឲ្យក្លាយជាអនុប្រធានស្រុក ២១។ នៅក្នុងឯកសារក៏បានបង្ហាញថា លោក **រម៉ម យុន**

និងសមាជិកប្រាំបួននាក់ទៀតត្រូវបានគេកោះហៅឲ្យចេញដំណើរមកភ្នំពេញដើម្បីជួយដាំដំឡូង។ មួយខែក្រោយមក ខ្មែរក្រហមបានបញ្ជូនគាត់ និងដើមបណ្តឹងរដ្ឋប្បវេណី **ក្លាន ហ្វីត** អមដំណើរដោយកម្មាភិបាលចំនួនពីរនាក់បាននាំពួកគាត់ឲ្យទៅកាន់វត្តស្លែង ខណៈដែលអ្នកនៅសេសសល់ក្នុងចំណោមកម្មាភិបាលរួមដំណើរជាមួយពួកគាត់ផ្សេងទៀតត្រូវបានគេចាប់ខ្លួន ហើយបញ្ជូនទៅកាន់មន្ទីរសន្តិសុខទួលស្លែង។ លោក **រម៉ម យុន** បានថ្លែងថា គោលបំណងនៃការដាក់ពាក្យបណ្តឹងសុំក្លាយខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៅកាន់ **អ.វ.ត.ក** គឺដើម្បីទាមទាររកយុត្តិធម៌លើការបាត់ខ្លួនមិត្តភក្តិរបស់គាត់ប្រាំមួយនាក់នោះ។ លោក **រម៉ម យុន** បានផ្តល់សក្ខីកម្មថា គាត់ត្រូវបានខ្មែរក្រហមបញ្ជាឲ្យគាត់សរសេរប្រវត្តិរូបសង្ខេបនៅពេលដែលគាត់បានមកដល់ទីក្រុងភ្នំពេញភ្លាមៗ។

នៅពេលមានការចោទសួរពីមេធាវីការពារក្តី លោក **រម៉ម យុន** ជារឿយៗបានអះអាងថា លោកចាំមិនច្បាស់ទេអំពីព្រឹត្តិការណ៍នានាដែលបានកើតឡើងនៅឆ្នាំ១៩៧៥។ ដូចនេះហើយ គាត់ក៏មិនបានឆ្លើយនូវសំណួរមួយចំនួនដែរ។ មេធាវីអន្តជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោក **បាណាបេ ណេគ្វី** *(Mr. Barnabe Nekuie)* បានធ្វើការចង្អុលបង្ហាញថា កូនក្តីរបស់គាត់មិនសូវមានការចងចាំប៉ុន្មានទេ។ គាត់បានជំទាស់ពីរបៀបសួរសំណួររបស់មេធាវីការពារក្តីលោក **អាង ឧត្តម** ដោយបានធ្វើការកត់សម្គាល់ថា មេធាវីការពារក្តីមានចេតនាទាញយកផលចំណេញនៃភាពមិនចងចាំរបស់ដើមបណ្តឹងរដ្ឋប្បវេណី **រម៉ម យុន**។ អង្គជំនុំជម្រះ បានសម្រេចលើសេចក្តីជំទាស់របស់មេធាវី **បាណាបេ** ថាមិនមានប្រសិទ្ធភាព និងបានអនុញ្ញាតឲ្យមេធាវី **អាង ឧត្តម** បន្តតាំងសំណួររបស់គាត់ទៅដើមបណ្តឹងរដ្ឋប្បវេណី។ មិនមានក្រុមមេធាវីការពារក្តីដទៃទៀត ធ្វើការសួរដេញដោលលើលោក **រម៉ម យុន** ទេ។[2]

ជាទូទៅ នៅពេលមានសំណួរសួរពីចៅក្រមនៃអង្គជំនុំជម្រះ ជាពិសេសបើជាសំណួរចេញពីចៅក្រមអន្តរជាតិ លោក **រម៉ម យុន** ហាក់បីដូចជាមានការភាន់ច្រឡំក្នុងការផ្តល់សក្ខីកម្មរបស់គាត់ ដែលប្រការនេះអាចមកពីអ្នកបកប្រែស្តាប់ការនិយាយរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនច្បាស់ក៏ថាបាន។ ចម្លើយដែលគាត់បានឆ្លើយហាក់បីដូចជាមិនចំទៅនឹងសំណួរដែលបានសួរគាត់ឡើយ។ ឧទាហរណ៍ នៅពេលដែលចៅក្រម **ហ្សង់ម៉ាក ឡាវែរ៍** *(Jean-MarcLAVERGNE)* សួរគាត់ ថាតើគាត់នៅចាំទេថាមានព្រឹត្តិការណ៍អ្វីខ្លះបានកើតឡើងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយថា គាត់មិនចាំទេ ហើយក៏មិនអាចឆ្លើយបានដែរទាល់តែជួយរម្លឹកគាត់ឡើងវិញ។ ពេលដែលចៅក្រម **ឡាវែរ៍** បានសួរបញ្ជាក់ថា តើលោក **រម៉ម យុន** ដឹងថាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នោះ ជាថ្ងៃអ្វីរបស់ខ្មែរក្រហម? លោក **រម៉ម យុន** បានឆ្លើយតបថា គាត់មិនបានដឹងទេ។ ភាពភាន់ច្រឡំ និងភ្លេចភ្លាំងនៅតែបន្តកើតឡើងជាហូរហែដែលបង្កឲ្យមានចម្ងល់ ថាតើសក្ខីកម្មរបស់លោក **រម៉ម យុន** អាចនឹងនាំឲ្យមានការប៉ះពាល់ដល់ទម្ងន់នៃភស្តុតាង ដែលអង្គជំនុំជម្រះនឹងត្រូវភ្ជាប់ជាមួយនឹងសក្ខីកម្មរបស់គាត់ដែរឬទេ។

### គ.	សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្លាន ហ្វីត

លោក **ក្លាន ហ្វីត** ជាអតីតខ្មែរក្រហមមួយរូប ក៏ត្រូវបានកោះហៅដោយអង្គជំនុំជម្រះឲ្យមកបន្តការផ្ដល់សក្ខីកម្មក្នុងសប្ដាហ៍នេះ បន្ទាប់ពីសក្ខីកម្មរបស់គាត់ត្រូវបានផ្អាកកាលពីខែធ្នូ។ នៅថ្ងៃអង្គារ ទី១០ ខែមករា ឆ្នាំ២០១២ នេះ ភាគីសហព្រះរាជអាជ្ញា បានតាំងសំណួរទៅលើរូបគាត់ផ្ដែកលើព្រឹត្តិការណ៍មុនឆ្នាំ១៩៧៥ រីឯក្រុមមេធាវីការពារក្ដី បានបន្តសួរនៅថ្ងៃបន្ទាប់។

យោងតាមលោក **ក្លាន ហ្វីត** បានឲ្យដឹងថា មានបុគ្គលម្នាក់ឈ្មោះ **តាំង ស៊ី** បានណែនាំឲ្យគាត់ចូលរួមក្នុងចលនាបដិវត្តន៍។ បុរសជនជាតិឡាវរូបនេះ តាមដឹងមកថា ជាអ្នកដែលបានចូលរួមក្នុងចលនាបដិវត្តន៍តាំងពីពេលលោក **ក្លាន ហ្វីត** នៅជាយុវជនម្ល៉េះ ហើយបុគ្គលនេះ ក៏ជាអ្នកដែលបានប្រាប់លោក **ក្លាន ហ្វីត** ថា បើមិនចូលរួមក្នុងបដិវត្តន៍ទេ គាត់នឹងអាចត្រូវបានគេចាត់ទុកថាជាសត្រូវ ហើយនឹងយកទៅសម្លាប់។ លោក **ក្លាន ហ្វីត** បានថ្លែងថា គាត់ចូលរួមចលនាបដិវត្តន៍ដោយមិនដឹងថាតើពាក្យបដិវត្តន៍នេះមានន័យយ៉ាងដូចម្ដេច មានគោលជំហរអ្វី ហើយមានប្រភពចេញពីបក្សណាក៏មិនដឹងដែរ។ គាត់គ្រាន់តែធ្វើតាមការបញ្ជារបស់គេតែប៉ុណ្ណោះ ព្រោះតែភាពភ័យខ្លាច។

ទាក់ទងនឹងការជួបផ្ទាល់ជាមួយនឹងជនជាប់ចោទ **អៀង សារី** លោក **ក្លាន ហ្វីត** បានថ្លែងថា គាត់បានជួបលោក **អៀង សារី** ពីរដងមុនឆ្នាំ១៩៧០៖ ម្ដងនៅ*៩៥* អូរដាំង[3] នឹងម្ដងទៀតនៅភូមិចាយ។ លោក **ក្លាន ហ្វីត** បានថ្លែងថា នៅពេលគាត់កំពុងតែធ្វើការដាំដុះនៅទីនោះ ស្រាប់តែមានទាហានពីរនាក់បានដើរសំដៅមកកាន់គាត់ និងបានប្រាប់ថា អ៊ំ **អៀង សារី** ឲ្យមកហៅគាត់ទៅចូលរួមប្រជុំនៅការិយាល័យក-៥។ លោក **ក្លាន ហ្វីត** បានឲ្យដឹងថា លោក **អៀង សារី** បានធ្វើការកត់សម្គាល់ថា លោក **ក្លាន ហ្វីត** គឺជាអ្នកដែលបានមកដល់ក្រោយគេ និងថែមទាំងបានណែនាំថាបើគាត់មិនចូលរួមបដិវត្តន៍ទេ គាត់នឹងមិនមានអ្វីហូបចុកឡើយ។ លោក **ក្លាន ហ្វីត** បានអះអាងបន្ថែមទៀតថា លោក**អៀង សារី** បានបង្ខំគាត់ឲ្យចូលរួមបដិវត្តន៍។ លោក **ក្លាន ហ្វីត** បានថ្លែងថា គាត់បានឃើញលោក **អៀង សារី** ជាលើកទីពីរក្នុងកិច្ចប្រជុំមួយនៅភូមិចាយ មុនពេលរំដោះបានទីក្រុងភ្នំពេញកាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ នៅពេលនោះ គាត់ឃើញមានវត្តមានរបស់ប្រធានតំបន់ មេស្រុក មេឃុំមួយចំនួនបានចូលរួម ដោយឡែក រូបគាត់ផ្ទាល់ពេលនោះមានឋានៈជាមេឃុំតាឡាវ។

លោក **ក្លាន ហ្វីត** បានចង្អុលបង្ហាញថាលោក **អៀង សារី** រួមជាមួយនឹងអ្នកដឹកនាំជាន់ខ្ពស់ដទៃទៀតជាអ្នកដែលបានចេញបញ្ជាឲ្យមានការជម្លៀសពីភ្នំពេញទៅជនបទ។ លោកបានអះអាងថា មានតែលោក **អៀង សារី** និងអ្នកដឹកនាំជាន់ខ្ពស់ទាំងនោះតែប៉ុណ្ណោះ ដែលមានអំណាចចេញបញ្ជាឲ្យមានការជម្លៀស ហើយក៏មានអំណាចបង្គាប់ និងធានាថាបទបញ្ជារបស់ខ្លួន គឺត្រូវបានអ្នកក្រោមបង្គាប់អនុវត្តតាម។

នៅពេលដែលសហព្រះរាជអាជ្ញា បានសួរគាត់ថាតើធ្លាប់បានជួបជាមួយលោក **នួន ជា** ដែរឬទេ? លោក **ក្លាន ហ្វីត** បានឲ្យដឹងថា នៅមុនឆ្នាំ១៩៧៥ គាត់ធ្លាប់បានចូលរួមវគ្គសិក្សានយោបាយមួយដែលដឹកនាំដោយលោក **នួន ជា**។ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបានរ៉ាយរ៉ាប់ថា ប្រធានបទអប់រំដែលលោក **នួន ជា** បានលើកឡើងពិភាក្សាក្នុងការប្រជុំនាពេលនោះ រួមមានដូចជា៖ ភាពឯករាជ្យម្ចាស់ការ ក្រមសីលធម៌បក្ស ហើយនឹងការធានាឲ្យមានសន្តិភាព។ លោក **ក្លាន ហ្វីត** បានទទួលស្គាល់ថា គាត់មិនបានឃើញមុខលោក **នួន ជា** ដោយផ្ទាល់ទេ ដោយសារពេលនោះ មានអ្នកចូលរួមពី៥០០ ទៅ ៦០០នាក់ឯណោះ ក៏ប៉ុន្តែគាត់បានឮការណែនាំថាលោក **នួន ជា** គឺជាប្រធាននៃកិច្ចប្រជុំ។ លោក **ក្លាន ហ្វីត** បានបកស្រាយថា ក្រៅពីដឹងថាជនជាប់ចោទជាប្រធានអង្គប្រជុំ គាត់មិនបានដឹងពីមុខងាររបស់លោក **នួន ជា** ក្នុងចលនាបដិវត្តន៍ថាមានតួនាទីអ្វីនោះឡើយ។

នៅពេលភាគីចោទសួរទាក់ទងនឹងលោក **ខៀវ សំផន** លោក **ក្លាន ហ្វីត** បាននិយាយបន្ថែមទៀតថា គាត់មិនធ្លាប់បានជួបជាមួយនឹងអតីតគណៈប្រធានរដ្ឋរូបនេះទេ ហើយគាត់ក៏មិនបានដឹងឮពីមុខងារក្រោយៗមកទៀតរបស់ជនជាប់ចោទនេះដែរ ក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ។ បើប្រៀបធៀបទៅនឹងអត្តចរិតរបស់លោក **ក្លាន ហ្វីត** ក្នុងការផ្ដល់សក្ខីកម្មកាលពីខែធ្នូ បានបង្ហាញឲ្យឃើញថា ដើមបណ្ដឹងរដ្ឋប្បវេណី ហាក់ដូចជាបានសម្ដែងនូវអារម្មណ៍ជឿជាក់ជាងមុនក្នុងការបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ។ លើសពីនេះ ថ្វីត្បិតតែគាត់បានបង្ហាញពីការលំបាករបស់គាត់ជាញឹកញាប់ក្នុងការរម្លឹកឡើងវិញនូវព្រឹត្តិការណ៍ ដែលបានកើតឡើងក្នុងរបបនេះ គាត់ក៏អាចឆ្លើយតបនឹងសំណួរបានយ៉ាងស៊ីចង្វាក់គ្នាយ៉ាងល្អ ដោយមិនចាំបាច់មានជំនួយពីបុគ្គលិករបស់អង្គភាពគាំពារសាក្សី និងជនរងគ្រោះដូចពេលមុនទេ។

## ឃ. ការធ្វើកំណត់សម្គាល់របស់ជនជាប់ចោទ ខៀវ សំផន

បុគ្គលចុងក្រោយដែលអង្គជំនុំជម្រះ បានកោះហៅឲ្យចូលខ្លួននៅក្នុងបន្ទប់សវនាការនៅសប្ដាហ៍នេះគឺលោក **ខៀវ សំផន**។ នៅដើមដំបូងនៃសក្ខីកម្មរបស់គាត់ លោក **ខៀវ សំផន** បានបញ្ជាក់យ៉ាងច្បាស់ថា គាត់នឹងមិនឆ្លើយតបទៅនឹងសំណួរណាមួយដែលទាក់ទងនឹងប្រវត្តិសាវតានៃរបបកម្ពុជាប្រជាធិបតេយ្យទេ ហើយគាត់ក៏មិនមានមតិយោបល់អ្វីបន្ថែមលើសេចក្ដីថ្លែងការណ៍ដែលគាត់បានធ្វើកាលពីខែធ្នូ ឆ្នាំ២០១១ ដែរ ។ ជនជាប់ចោទបានថ្លែងទៀតថា ទៅថ្ងៃខាងមុខៗនៃសវនាការ គាត់នឹងឆ្លើយបំភ្លឺនូវសំណួរទាំងឡាយណាដែលពាក់ព័ន្ធនឹងរចនាសម្ព័ន្ធផ្នែករដ្ឋបាលនៃរបបនេះ ។ ទោះជាយ៉ាងណាក្ដី ចៅក្រម **ឡាវែន៍** បានបន្តព្យាយាមជជីកសួរសំណួរទៅកាន់ជនជាប់ចោទអំពីប្រវត្តិនៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយបានជោគជ័យតិចតួចដែរ។ បន្ថែមពីនេះ ចៅក្រម **ឡាវែន៍** ក៏បានស្នើឲ្យលោក **ខៀវ សំផន** ផ្ដល់ជាមតិយោបល់ ឬធ្វើការបញ្ជាក់ពីចម្លើយមួយចំនួនដែលជនជាប់ចោទធ្លាប់បានឆ្លើយទៅកាន់សហចៅក្រមស៊ើបអង្កេត កាលពីខែធ្នូ ឆ្នាំ២០០៧ ទាក់ទងទៅនឹងមុខងាររបស់គាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយដកស្រង់ខ្លឹមសារនៃឃ្លាមួយដូចតទៅនេះ៖ "តួនាទីរបស់ខ្ញុំជា

ប្រូតាកូល (គ្រាន់តែជាពិធីការ) តែប៉ុណ្ណោះ។ អ្នកទាំងអស់គ្នាបានដឹងហើយថា **ប៉ុល ពត** គាត់បានចាត់ទុកខ្ញុំថាជាកូនរបស់វណ្ណៈសក្តិភូមិដែលរលំរលាយ ហើយជាបញ្ញាជនស្នេហាជាតិដែលមិនមានឥទ្ធិពលអ្វីទាល់តែសោះនៅក្នុងសង្គម"។ ជាការឆ្លើយតបលោក **ខៀវ សំផន** បានពន្យល់ថា ការដកស្រង់ដែលចៅក្រម **ឡាវែន៍** បានអានចេញពីផ្នែកមួយនៃចម្លើយដែលគាត់ឆ្លើយជាមួយចៅក្រមស៊ើបអង្កេត គឺស្របគ្នានឹងការថ្លែងរបស់គាត់នៅខែធ្នូ ឆ្នាំ២០១១។ លោក **ខៀវ សំផន** គ្រាន់តែបានបន្ថែមទៀតថា ការដកស្រង់នេះឆ្លុះបញ្ចាំងពីលក្ខខណ្ឌនៃការបញ្ចូលឈ្មោះគាត់ទៅក្នុងគណៈមជ្ឈិមបក្សដែលពេលនោះបក្សបញ្ចូលឈ្មោះគាត់ គឺធ្វើឡើងដោយការអនុគ្រោះតែប៉ុណ្ណោះ (មានន័យថា បក្សតម្រូវឲ្យថ្នាក់ដឹកនាំត្រូវតែមានវណ្ណៈកសិករក្រីក្រ)។ ជនជាប់ចោទ **ខៀវ សំផន** បានបញ្ជាក់ប្រាប់តុលាការថា គាត់មិនមានលក្ខណៈសម្បត្តិពេញលេញ ដើម្បីអាចចូលជាសមាជិកបក្សបានទេព្រោះតែគាត់ជាកូនរបស់សក្តិភូមិ ហើយទស្សនៈវិស័យរបស់គាត់មិនស៊ីចង្វាក់គ្នាជាមួយនឹងមាគ៌ាបក្សកុម្មុយនីស្តកម្ពុជាឡើយ ។

ក្រៅពីការធ្វើអត្ថាធិប្បាយទាំងនេះចប់លោក **ខៀវ សំផន** បានដាក់កម្រិតលើចម្លើយតបរបស់គាត់ និងបានបញ្ជាក់ថា គាត់បានសរសេរសៀវភៅមួយដែលមានចំណងជើងថា*"ប្រវត្តិសាស្ត្រកម្ពុជាថ្មីនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់"* ដែលសៀវភៅនេះ បានរៀបរាប់រឿងរ៉ាវលម្អិតអំពីរូបគាត់។ លោកចៅក្រម **ឡាវែន៍** បានបន្តស្នើឲ្យជនជាប់ចោទធ្វើអត្ថាធិប្បាយនូវសម្រង់ខ្លីៗ ដោយអានចេញពីឯកសារផ្សេងៗ ប៉ុន្តែជនជាប់ចោទបានធ្វើការបដិសេធយ៉ាងច្បាស់លាស់ ចំពោះការមិនព្រមឆ្លើយតបទៅនឹងសំណួរនានា ហើយក៏មិនផ្តល់នូវការអត្ថាធិប្បាយបន្ថែមទៀតដែរ។

## *ជំពូកទី៣ ៖* បញ្ហាច្បាប់ និង នីតិវិធី

ការវិវឌ្ឍន៍នៃសវនាការនៅក្នុងសប្តាហ៍នេះ បានប្រឈមនឹងបញ្ហានីតិវិធីលើការទទួលស្គាល់ឯកសារជាឯកសារភស្តុតាងដោយសារតែចំនួននៃឯកសារដ៏ច្រើនលើសលុប អាចនឹងត្រូវតែដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ ហើយនិងបញ្ហានៃការប្រើប្រាស់ឯកសារថតចម្លងជំនួសឲ្យឯកសារដើម។ បញ្ហាផ្សេងពីនេះមួយទៀតតម្រូវឲ្យមានការគូសបញ្ជាក់ឲ្យបានច្បាស់លាស់នោះ គឺទាក់ទងនឹងការបកស្រាយរបស់អង្គជំនុំជម្រះអំពីសិទ្ធិនៅស្ងៀមស្ងាត់មិនឆ្លើយតបរបស់ជនជាប់ចោទ លោក **អៀង សារី** និងលោក **ខៀវ សំផន**។ បញ្ហាចុងក្រោយដែលត្រូវបានភាគីជជែកពិភាក្សាគ្នាដែរនោះគឺ ស្តីអំពីវិសាលភាពនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងការចោទប្រកាន់លើការជ្រៀតជ្រៀកនយោបាយពីរាជរដ្ឋាភិបាលកម្ពុជា ។

### ក. ការទទួលយកឯកសារ និងយថាភាពនៃឯកសារភស្តុតាងដែលមាននៅក្នុងសំណុំរឿង

នៅថ្ងៃចុងក្រោយនៃសវនាការក្នុងខែធ្នូ ឆ្នាំ២០១១[4] មេធាវីការពារលោក **នួន ជា** បានជំទាស់ទៅនឹងការបង្ហាញឯកសារថតចម្លងក្នុងប្រព័ន្ធអេឡិចត្រូនិច (ទស្សនាវដ្ដីទង់បដិវត្តន៍) ក្រោមហេតុផលថា បញ្ហាយថាភាពនៃកំណត់ត្រាដែលមានក្នុងទស្សនាវដ្ដីនេះ នៅតែមានភាពស្រពិចស្រពិលនៅឡើយ (មិនច្បាស់ថាជាឯកសារដែលខ្លឹមសារខាងក្នុងពិត ឬក្លែងដោយបុគ្គល ឬក្រុមណាមួយ) ។ លោក **នួន ជា** បានទាមទារម្ដងហើយម្ដងទៀត ដើម្បីសុំមើលឯកសារដើមនៃទស្សនវដ្ដីទង់បដិវត្តន៍ ដោយបានចង្អុលបង្ហាញអំពីភាពមិនប្រក្រតីមួយចំនួនដែលមាននៅក្នុងទស្សវដ្ដីដាក់បង្ហាញដោយសហព្រះរាជអាជ្ញា ដូចជាភាពខុសគ្នានៃឃ្លាឃ្លោងជាក់លាក់រវាងឯកសារថតចម្លង និងអ្វីដែលគាត់ចងចាំទាំងរូបរាង និងខ្លឹមសារនៅក្នុងឯកសារដើម ។

អង្គជំនុំជម្រះ បានបដិសេធលើសេចក្ដីជំទាស់ធ្វើឡើងដោយមេធាវីការពារក្ដី ដោយបានកត់សម្គាល់ថាតុលាការមានសេរីភាពទូលំទូលាយក្នុងការសម្រេចកំណត់យកភស្តុតាងផ្អែកតាមវិធាន៨៧.១ នៃវិធានផ្ទៃក្នុង និងបានបញ្ចប់ដោយថ្លែងថា វាមិនមានមូលដ្ឋានណាមួយ ដើម្បីច្រានចោលឯកសារដោយយោងតាមវិធានផ្ទៃក្នុងវិធាន៨៧.៣ ឡើយ។ លោកចៅក្រម **ឡាវ៉ែន** បានពន្យល់បន្ថែមទៀតថា ខណៈពេលដែលឯកសារនៅក្នុងសំណុំរឿងទាំងនេះ ត្រូវបានចាត់ទុកថា បានទទួលស្គាល់រួចហើយ អង្គជំនុំជម្រះនឹងពិចារណានូវតម្លៃនៃភស្តុតាងនៅដំណាក់កាលក្រោយៗទៀត ហើយនឹងបន្ថយទម្ងន់ចំពោះភស្តុតាងឯកសារទាំងឡាយដែលយថាភាពនៃឯកសារទាំងនោះនៅចោទជាបញ្ហា ឬមានវិវាទកម្ម។ ទោះបីជាមានការសម្រេចដោយអង្គជំនុំជម្រះក៏ដោយ ក៏លោក **នួន ជា** នៅតែបន្តទាមទារសុំឲ្យភាគីម្ចាស់សំណួរបង្ហាញឯកសារដើមឲ្យគាត់មើលមុន នៅពេលមានការស្នើឲ្យគាត់ធ្វើការបញ្ជាក់ពីខ្លឹមសារផ្សេងៗក្នុងឯកសារទាំងនោះ ។ ដូចគ្នាផងដែរ មេធាវីការពារក្ដីអន្តរជាតិរបស់គាត់ គឺលោក **ម៉ៃខល ផេសមិន** *(Mr. Michiel PESTMAN)* ក៏បានទទូចដោយលើកឡើងអំពីបញ្ហាយថាភាពនៃឯកសារចម្លងអេឡិចត្រូនិច។ ចំណែកឯលោក **សុន អរុណ** ជាមេធាវីជាតិការពារក្ដីឲ្យលោក **នួន ជា** ក៏បានស្នើសុំឲ្យមានការបញ្ជាក់នូវមូលដ្ឋាននៃសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះដោយលោកមេធាវីបានសម្អាងលើហេតុផលថា តុលាការជាតិរបស់កម្ពុជា បានតម្រូវឲ្យមានការបង្ហាញនូវឯកសារដើមចំពោះការសម្រេចថា យកឯកសារណាមួយជាភស្តុតាងបាន ។

លោក **វីល្លៀម ស្មីត** *(Mr. William Smith)* សហព្រះរាជអាជ្ញាអន្តរជាតិ បានធ្វើការអះអាងថា តាមច្បាប់ព្រហ្មទណ្ឌអន្តរជាតិវិញ គឺថាមិនចាំបាច់បង្ហាញនូវឯកសារដើមក៏បាន ។ វាអាចធ្វើទៅបាន លុះត្រាណាមានការសង្ស័យជាក់លាក់ទាក់ទងនឹងយថាភាពនៃឯកសារចម្លង។ លោក **ស្មីត** នៅតែអះអាងថា វាមិនចាំបាច់បង្ហាញឯកសារដើមទេ ពីព្រោះតែមេធាវីការពារលោក **នួន ជា** មិនបានធ្វើការចង្អុលបង្ហាញឲ្យឃើញនូវចំណុចសង្ស័យជាក់លាក់ណាមួយជំទាស់ទៅនឹងយថាភាពនៃឯកសារនោះទេ។ លោក **ស្មីត** បានផ្ដល់យោបល់ថា ការទាមទាររបស់

ជនជាប់ចោទឲ្យបង្ហាញឯកសារដើម គឺគ្មានហេតុផល ព្រោះតែការទាមទារមិនឆ្លុះបញ្ចាំងនូវចំណុចសង្ស័យជាក់លាក់អំពីយថាភាពនៃឯកសារនោះ និងថា ការធ្វើដូចនេះ គ្រាន់តែជាមធ្យោបាយចង់ពន្យារពេលនីតិវិធីប៉ុណ្ណោះ។ លោក **ស្មឹត** បានព្រមានដោយបានហាមលោក **នួន ជា** ថាការបន្តបដិសេធមិនឆ្លើយតបទៅនឹងសំណួរដោយសារតែមិនមានឯកសារដើមនោះ អាចជាលទ្ធផលធ្វើឲ្យអង្គជំនុំជម្រះបន្ថយនូវទម្ងន់សក្ខីកម្មរបស់គាត់នៅចុងបញ្ចប់នៃដំណើរការនីតិវិធីសំណុំរឿងនេះ បើគាត់នៅតែគេចវេសមិនឆ្លើយតប ។

ជាការឆ្លើយតបទៅនឹងការជំទាស់ម្តងហើយម្តងទៀត និងការបង្ហាញឲ្យឃើញច្បាស់ពីការមិនរសាយចិត្តរបស់ជនជាប់ចោទ អង្គជំនុំជម្រះបានពន្យល់ថា **អ.វ.ត.ក** ក៏ដូចជាតុលាការអន្តរជាតិដទៃទៀតដែរបានទទួលយកអនុវត្តន៍ឲ្យប្រើប្រាស់ប្រព័ន្ធឯកសារអេឡិចត្រូនិចនៅក្នុងសំណុំរឿង ក្នុងបំណងជំរុញឲ្យដំណើរការនីតិវិធីប្រព្រឹត្តទៅកាន់តែបានឆាប់រហ័ស ដោយសារតែទំហំនៃឯកសារក្នុងសំណុំរឿងមានច្រើនលើសលុប ។ មេធាវីការពារក្តីអន្តរជាតិ លោក **ម៉ៃខល កាណាវ៉ាស** *(Mr. Michael Karnavas)* បានចង្អុលបង្ហាញថា ជាការពិតដែលតុលាការព្រហ្មទណ្ឌអន្តរជាតិមិនតម្រូវឲ្យដាក់បង្ហាញឯកសារដើមនៅចំពោះជនជាប់ចោទ ក៏ប៉ុន្តែគេទាមទារឲ្យអ្នករក្សាទុកឯកសារទាំងនោះមកឆ្លើយបំភ្លឺ។ មេធាវីជាតិរបស់លោក **ខៀវ សំផន** គឺលោកមេធាវី **គង់ សំអុន** បានបន្ថែមថា ខណៈពេលដែលការប្រើប្រាស់ឯកសារចម្លងអាចជួយសម្រួលដល់នីតិវិធីនៃសវនាការបាន វាក៏គួរតែត្រូវបានគេចោទសួរផងដែរថា តើឯកសារចម្លងទាំងនេះ ជាឯកសារដើមពិតប្រាកដ ហើយតើប្រភពពិតនៃឯកសារនោះត្រូវបានរក្សាទុកបានល្អដែរ ឬទេ។

អង្គជំនុំជម្រះ បានបង្អកទុកការជជែកដេញដោលទាំងនេះមួយអន្លើ ដោយមិនធ្វើសវនាការក្នុងសប្តាហ៍បន្ទាប់ ដើម្បីបន្តរកដំណោះស្រាយ ឬស្តាប់នូវការដាក់សំណើផ្ទាល់មាត់លើបញ្ហានៃការទទួលឯកសារភស្តុតាង ក៏ដូចជាបញ្ហាយថាភាពនៃឯកសារឡើយ ។ ទោះជាដំណើរការនីតិវិធីសវនាការសប្តាហ៍នេះ ត្រូវបានចំណាយពេលជាច្រើន ដើម្បីដោះស្រាយនូវការជំទាស់ម្តងហើយម្តងទៀតពីសំណាក់ជនជាប់ចោទ ចំណោទសំណួរសំខាន់ៗនៅតែកើតមានឡើង ថាតើអង្គជំនុំជម្រះគួរដោះស្រាយបញ្ហានេះនៅដំបូងទីឲ្យចប់សព្វគ្រប់សិន ឬទុកឲ្យបញ្ហានេះបន្តកើតមានឡើងក្នុងសវនាការក្រោយៗទៀត ។ ការដោះស្រាយនូវបញ្ហានេះ កាន់តែឆាប់ អាចនឹងទប់ស្កាត់នូវការជំទាស់តវ៉ាទៅវិញទៅមកលើបញ្ហាតែមួយជាដដែលៗពីភាគីនៃអង្គជំនុំជម្រះ ។

វាក៏មិនទាន់មានភាពច្បាស់លាស់ឡើយ ថាហេតុអ្វីបានជាអង្គជំនុំជម្រះកំណត់យកកាលវិភាគស្តាប់នូវការតវ៉ាដេញដោលផ្ទាល់មាត់ដោយប្រើរយៈពេលបី ឬបួនសប្តាហ៍ក្នុងខែមករា នៅពេលដែលអង្គជំនុំជម្រះ បានដឹងចាប់តាំងពីមុនពេលវិសមកាលរបស់តុលាការមកម្ល៉េះថា បញ្ហាទាំងនេះ គឺជារឿងដ៏ក្តៅគគុកមួយដែលត្រូវបានជំទាស់តវ៉ាដោយក្រុមការពារក្តី។ យើងសង្ឃឹមទុកថា អង្គជំនុំជម្រះ នឹងបង្កើតនូវវិធានការច្បាស់លាស់នៅក្នុង

ដំណើរការសវនាការបន្តបន្ទាប់ទៀត ព្រមទាំងធានាឲ្យមានតម្លាភាពជាស្តង់ដារមួយស្តីពីការទទួលយកឯកសារ និងយថាភាពរបស់វា ។

### ខ. សិទ្ធិនៅស្ងៀមមិនឆ្លើយតប

មានការខ្វែងគំនិតគ្នានៅក្នុងសប្តាហ៍នេះ នៅពេលមានការលើកឡើងពីសិទ្ធិនៅស្ងៀមស្ងាត់មិនឆ្លើយតប ប្រឈមនឹងការព្យាយាមសួរសំណួរជាច្រើនដងពីអង្គជំនុំជម្រះទៅកាន់ជនជាប់ចោទ។ ដូចបានធ្វើកំណត់សម្គាល់ខាងលើ ហេតុការណ៍ជាក់ស្តែងបានកើតឡើងនៅរសៀលថ្ងៃព្រហស្បតិ៍ នៅពេលដែលអង្គជំនុំជម្រះបានកោះហៅឲ្យលោក **ខៀវ សំផន** ផ្តល់សក្ខីកម្ម ទោះបីជាជនជាប់ចោទបានថ្លែងបញ្ជាក់រួចហើយថាគាត់នឹងមិនផ្តល់សក្ខីកម្មទេ។ លោកប្រធានអង្គជំនុំជម្រះ បានគូសបញ្ជាក់ថា មានការភាន់ច្រឡំថាតើលោក **ខៀវ សំផន** ចង់ផ្តល់សក្ខីកម្មតែលើអង្គហេតុជាក់លាក់ណាមួយ ឬយ៉ាងណា បើដូច្នេះមែននោះ វិសាលភាពនៃការចូលរួមរបស់គាត់ក៏នឹងត្រូវបានថ្លឹងថ្លែងក្នុងដែនកំណត់មួយដែរ។

លោក **គង់ សំអុន** បានធ្វើការឆ្លើយតប និងផ្តល់ជាយោបល់ទៅកាន់អង្គជំនុំជម្រះថា កូនក្តីខ្លួននឹងមិនផ្តល់សក្ខីកម្មទាំងឡាយណាដែលទាក់ទងនឹងប្រវត្តិសាវតានៃរបបកម្ពុជាប្រជាធិបតេយ្យទេ។ លោកមេធាវី ក៏បានបញ្ជាក់ទៀតថា កូនក្តីរបស់គាត់កំពុងប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប។ រីឯលោក **ខៀវ សំផន** ផ្ទាល់ ក៏បានអះអាងបន្ថែថា អ្វីដែលមេធាវីរបស់គាត់និយាយជាការពិត និងបានបន្ថែមថា គាត់អាចនឹងឆ្លើយនូវសំណួរទាំងឡាយណាដែលទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាលនៃរបបកម្ពុជាប្រជាធិបតេយ្យឡើយ។

ទោះយ៉ាងណាក៏ដោយ ចៅក្រម **ឡាវែន៍** បានចាប់ផ្តើមពន្យល់ទៅកាន់ជនជាប់ចោទរូបនេះថា អង្គជំនុំជម្រះធ្វើការកោះហៅជនជាប់ចោទឲ្យចូលខ្លួនមកផ្តល់សក្ខីកម្មដោយសារៈ ទី១ ស្នើឲ្យជនជាប់ចោទជួយផ្តល់មតិយោបល់បញ្ជាក់លើប្រតិកម្មតបរបស់ខ្លួនទៅកាន់សេចក្តីសន្និដ្ឋានបើកការចោទប្រកាន់ ដោយសហព្រះរាជអាជ្ញាកាលពីខែធ្នូ ជាពិសេស ការឆ្លើយតបទាំងឡាយណាដែលមានការជាប់ទាក់ទិននឹងបទចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ព្រមទាំងជីវប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា។ ទី២ ស្នើឲ្យជនជាប់ចោទផ្តល់ការមតិយោបល់បញ្ជាក់លើខ្លឹមសារក្នុងឯកសារជាក់លាក់មួយចំនួន ដែលអង្គជំនុំជម្រះយល់ថាមានសារៈសំខាន់ទាក់ទងនឹងប្រវត្តិនៃការកកើតបក្សកុម្មុយនីស្តកម្ពុជា។ ដើម្បីជំរុញឲ្យលោក **ខៀវ សំផន** "ផ្លាស់ប្តូរចិត្តគំនិតរបស់គាត់" ចៅក្រម **ឡាវែន៍** បានព្យាយាមធ្វើយ៉ាងណាឲ្យបានការឆ្លើយបញ្ជាក់ពីជនជាប់ចោទ ដោយបានអាននូវសម្រង់ខ្លីៗពីឯកសារនានាក្នុងបំណងចង់ឲ្យមានការផ្តល់អត្ថាធិប្បាយ ដោយអានចេញនូវការដកស្រង់ពីឯកសារ ដែលត្រូវបានជ្រើសរើសផ្ទាល់ដោយអង្គជំនុំជម្រះ។ លោក **គង់ សំអុន** បានធ្វើការជំទាស់ជាច្រើនដង និងបានរម្លឹកអង្គជំនុំជម្រះលើការអនុវត្តន៍សិទ្ធិមិនឆ្លើយតបរបស់ជនជាប់ចោទ ។ លោកមេធាវី បានថ្លែងថា អង្គជំនុំជម្រះមិនបានគោរពសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់កូនក្តីគាត់ទេ ដរាបណាអង្គជំនុំជម្រះនៅតែបន្តតាំងសំណួរទៅកាន់លោក **ខៀវ សំផន**

និងស្នើឲ្យគាត់ធ្វើការឆ្លើយបញ្ជាក់យ៉ាងដូចនេះ។ ការធ្វើដូចនេះ បានន័យថា លោក **ខៀវ សំផន** ត្រូវតែឆ្លើយតប ហើយការធ្វើដដែលៗបែបនេះ វាបង្ហាញយ៉ាងច្បាស់ថា អង្គជំនុំជម្រះកំពុងតែបង្ខំឲ្យលោក **ខៀវ សំផន** ត្រូវតែឆ្លើយតបសូម្បីតែគាត់បានបញ្ជាក់ម្តងហើយម្តងទៀតថា គាត់ប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបលើសម្រង់ខ្លីៗដែលបានអាននៅចំពោះមុខគាត់នេះទេ ។ ដោយឡែក ជនជាប់ចោទ វិញ នៅពេលមានការទទូចឲ្យឆ្លើយបញ្ជាក់លើការអាននូវសម្រង់ខ្លីៗធ្វើដោយចៅក្រម **ឡាវ៉ែន** លោក **ខៀវ សំផន** បានត្រឹមតែឆ្លើយថា គាត់គ្មានអ្វីត្រូវបន្ថែមទៅនឹងអ្វីដែលគាត់បានថ្លែងពីមុនមកទេ។

ព្រឹត្តិការណ៍សំខាន់ៗទាំងនេះ បានឆ្លុះបញ្ចាំងនូវតម្រូវការចាំបាច់ ដែលអង្គជំនុំជម្រះត្រូវតែគូសបញ្ជាក់ឲ្យបានច្បាស់នូវការបកស្រាយរបស់ខ្លួនឆ្លើយតបនឹងសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទ ដោយសារតែវាមានការពិបាកយល់បាន ថាតើហេតុអ្វីបានជាលោក **ខៀវ សំផន** ត្រូវបានកោះហៅឲ្យមកផ្តល់សក្ខីកម្ម បើទោះណាជាលោក **ខៀវ សំផន** និងមេធាវីរបស់គាត់បានបកស្រាយយ៉ាងច្បាស់តាំងពីដំបូងទី ដោយមិនត្រឹមតែបានគូសបញ្ជាក់នូវពេលវេលាច្បាស់លាស់នោះទេ ថែមទាំងបានប្រកាសជាញយដងជូនដល់អង្គជំនុំជម្រះ និងភាគីថាលោក **ខៀវ សំផន** កំពុងតែអនុវត្តសិទ្ធិជាមូលដ្ឋានរបស់លោក។ ការទទូចរបស់អង្គជំនុំជម្រះ ទាមទារឲ្យជនជាប់ចោទផ្តល់ព័ត៌មានបន្ថែម ឬផ្តល់មតិយោបល់នានាមួយហើយមួយទៀតដូចនេះ វាហាក់បីដូចជាដាក់សម្ពាធឲ្យលោក **ខៀវ សំផន** ឆ្លើយតបអញ្ចឹងដែរ ។

### គ. ទំហំ និងទម្ងន់នៃភស្តុតាងដែលបានពីការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី

មកទល់ថ្ងៃនេះ ផ្នែកសំខាន់ៗនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ភាគច្រើនទាក់ទងនឹងអង្គហេតុពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ក្នុងដីកាបណ្តោះអាសន្ន ជាជាងការពិពណ៌នាលម្អិតអំពីការខូចខាត និងការរៀបរាប់ពីទុក្ខសោកផ្សេងៗ ដែលដើមបណ្តឹងរដ្ឋប្បវេណីគួរទាមទារ ដើម្បីគាំទ្រនៅក្នុងឋានៈពួកគេជាដើមបណ្តឹងរដ្ឋប្បវេណី។ ខណៈពេលដែលព័ត៌មាននៃអង្គហេតុដែលគេបានផ្តល់ អាចជួយឲ្យអង្គជំនុំជម្រះឈានដល់ការចេញសាលក្រមស្តាពរមួយ ចំពោះការចោទប្រកាន់ពីបទព្រហ្មទណ្ឌប្រឆាំងជនជាប់ចោទទាំងបី កង្វះខាតនៃសក្ខីកម្មអំពីការខូចខាតដោយផ្ទាល់មួយចំនួនដែលដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះបានជួបប្រទះ និងចំណងទំនាក់ទំនងមេត្រីភាពពិសេសដែលពួកគេមានជាមួយជនរងគ្រោះ អាចនឹងនាំឲ្យខូចប្រយោជន៍ដល់ការទាមទារសំណងនៅក្នុងដំណាក់កាលចុងក្រោយបាន ។ មកដល់ចំណុចនេះ ការពិនិត្យជាថ្មីចំពោះសក្ខីកម្មរបស់លោក **រ៉ម យុន** និងលោក **ភ្លាន ហ៊ីត** បានបង្ហាញថា ពួកគាត់ម្នាក់ៗបានលើកឡើងត្រឹមតែអង្គហេតុបញ្ចិតបញ្ចៀងប៉ុណ្ណោះ នៅក្នុងការឆ្លើយតបនឹងធាតុសំខាន់ ដើម្បីគាំទ្រដល់ការទាមទារក្នុងនាមពួកគាត់ជាដើមបណ្តឹងរដ្ឋប្បវេណី។ ហេតុផលទាំងនេះ បានធ្វើឲ្យមេធាវីការពារក្តីលើកឡើងនូវសេចក្តីព្រួយបារម្ភរបស់ពួកគេអំពីបញ្ហានៃការប្រើប្រាស់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីឲ្យបានត្រឹមត្រូវពីសំណាក់អង្គជំនុំជម្រះ ។ មេធាវីអន្តរជាតិការពារក្តីឲ្យលោក **នួន ជា** បានស្នើសុំឲ្យតុលាការ ធ្វើការបញ្ជាក់ថាតើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីអាចយកមក

ប្រើប្រាស់ជាភស្តុតាងដើម្បីគាំទ្រដល់ការផ្តន្ទាទោសលើជនជាប់ចោទ ឬថាតើសក្ខីកម្មរបស់ពួកគេត្រូវកម្រិតក្នុងដែនកំណត់ដ៏តឹងរឹងមួយដោយទទួលយកតែសក្ខីកម្មស្តីអំពីការរៀបរាប់នូវទុក្ខសោក និងការខូចខាតនៃលទ្ធផលបានមកពីបទឧក្រិដ្ឋនានាដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទ។ លោកមេធាវី **ផេស្តមិន** បានអះអាងថា ដោយសារតែលោក **រម៉ម យុន** គឺជាដើមបណ្តឹងរដ្ឋប្បវេណី( ជាភាគីនៃសំណុំរឿងតែមិនមានការតម្រូវឲ្យធ្វើសច្ចាប្រណិធាន ) និងក៏មិនមែនជាសាក្សីដែរ។ ដូច្នេះ មានន័យថា សក្ខីកម្មរបស់គាត់គួរតែត្រូវបានដាក់ក្នុងកម្រិតដែនកំណត់ត្រឹមតែការអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណី ធ្វើការថ្លែងតែអំពីការឈឺចាប់របស់គាត់ទើបជាការគួរ ។ លោកមេធាវី **ផេស្តមិន** បានថ្លែងនៅក្នុងសេចក្តីកត់សម្គាល់របស់ខ្លួនថា គ្មានអ្វីដែលបញ្ជាក់ថាសក្ខីកម្មរបស់លោក **រម៉ម យុន** បាននិយាយពាក់ព័ន្ធនឹងអង្គហេតុសំខាន់ៗពីរបបខ្មែរក្រហមឡើយ ។ លោកមេធាវីបានតវ៉ាទៀតថា របកគំហើញនៃសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី គឺមិនមានភាពពាក់ព័ន្ធទាល់តែសោះ ចំពោះកិច្ចដំណើរការនីតិវិធីសវនាការ ។ មេធាវីការពារក្តី **អាង ឧត្តម** បានយល់ស្របនូវការលើកឡើងរបស់មេធាវី **ផេស្តមិន** និងបានបន្ថែមថា អង្គជំនុំជម្រះ បានខ្ជះខ្ជាយពេលវេលាអស់ច្រើនមកហើយ ក្នុងការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលសក្ខីកម្មទាំងនោះភាគច្រើនមិនទាំងស្ថិតក្នុងដែនវិសាលភាពនៃការទាមទាររបស់ពួកគាត់ទៅទៀត ។ លោកមេធាវីបានសង្កត់ធ្ងន់ថា ដើមបណ្តឹងរដ្ឋប្បវេណី គឺមិនដូចគ្នានឹងសាក្សី ឬអ្នកជំនាញនោះទេ ដោយសារដើមបណ្តឹងរដ្ឋប្បវេណីមិនអាចបង្កើតភស្តុតាងដោយការអះអាងលើបទឧក្រិដ្ឋដែលប្រព្រឹត្តឡើងដោយជនជាប់ចោទបានឡើយ ។ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានទាញសម្អាងដែលមានចែងនៅក្នុងវិធានផ្ទៃក្នុងវិធាន២៣ នៃ **អ.វ.ត.ក** ថាបានផ្តល់លទ្ធភាពដល់ដើមបណ្តឹងរដ្ឋប្បវេណី អាចនិយាយនូវហេតុការណ៍ទាំងឡាយណាដែលទាក់ទងនឹងសំណុំរឿង។ ការលើកហេតុផលនេះ ត្រូវបានគាំទ្រ ដោយសហព្រះរាជអាជ្ញា លោក **វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល** *(Mr. Vincent de wilde d'ESTMAEL)*។ សហព្រះរាជអាជ្ញា បានផ្តល់យោបល់ថា ការតវ៉ារបស់ភាគីការពារក្តីអំពីតម្លៃ និងចំណងពាក់ព័ន្ធក្នុងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺមិនបានផ្តល់នូវការគោរពដល់ដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ សហព្រះរាជអាជ្ញា បានធ្វើសេចក្តីសន្និដ្ឋានថា ការកំណត់នូវសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋវប្បវេណី ត្រូវបានសម្រេចយ៉ាងប្រុងប្រយ័ត្នពីសំណាក់អង្គជំនុំជម្រះ។ វិធានផ្ទៃក្នុងនៃ**អ.វ.ត.ក** វិធាន២៣ (១) បានផ្តល់ឲ្យលទ្ធភាពឲ្យដើមបណ្តឹងរដ្ឋប្បវេណីនូវសេរីភាពយ៉ាងទូលំទូលាយតាមមធ្យោបាយដែលពួកគាត់មាន ដើម្បីជួយគាំទ្រដល់ការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ដោយការចូលរួមផ្តល់សក្ខីកម្មក្នុងដំណើរការនីតិវិធី ។ សក្ខីកម្មរបស់ពួកគេ គឺស្វះស្វែងធ្វើយ៉ាងណាជួយគាំទ្រដល់ភាគីសហព្រះរាជអាជ្ញាក្នុងការរកពិរុទ្ធភាពរបស់ជនជាប់ចោទ ពីព្រោះការទាមទារសំណងនានារបស់ពួកគេ បានភ្ជាប់ជាមួយនឹងការរកឃើញរបស់អង្គជំនុំជម្រះ នូវការទទួលខុសត្រូវរបស់ជនជាប់ចោទ ចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលបានបង្កឲ្យពួកគេទទួលរងគ្រោះ និងការខូចខាត ។ ទោះជាយ៉ាងណា បញ្ហាសំខាន់ជាងនេះទៅទៀត គឺសារៈសំខាន់នៃការគូសបញ្ជាក់ពីអង្គជំនុំជម្រះ ជាវិធីមួយនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីអាចនឹងត្រូវបានយកទៅប្រើប្រាស់ជាភស្តុតាងបន្ថែម តែបើគិតតាមផ្លូវមួយទៀតគឺថា សក្ខីកម្មរបស់ពួកគាត់នឹងផ្តល់ទម្ងន់តិចតួចជាងសក្ខីកម្មរបស់សាក្សី ពីព្រោះតែដើមបណ្តឹងរដ្ឋប្បវេណី គឺជាភាគីដែលទទួលបានផលប្រយោជន៍ផ្ទាល់ខ្លួនពី

សំណុំរឿង ហើយដែលសក្ខីកម្មរបស់ពួកគេ មិនអាចនឹងត្រូវបានប្រើប្រាស់ជាមូលដ្ឋានតែមួយនៃការផ្តន្ទាទោសផ្អែកលើបទចោទប្រកាន់ជាក់លាក់ប្រឆាំងនឹងជនជាប់ចោទណាមួយឡើយ ។

### ឃ. ការចោទប្រកាន់របស់មេធាវីការពារក្តី លោក នួន ជា ស្តីពីការជ្រៀតជ្រែកផ្នែកនយោបាយ

ជាថ្មីម្តងទៀត មេធាវីការពារក្តីលោក **នួន ជា** បានលើកឡើងនូវការព្រួយបារម្ភយ៉ាងខ្លាំង នៅក្នុងពេលតុលាការ ចាប់ផ្តើមបើកដំណើរការនៅសប្តាហ៍នេះ ស្តីពីការថ្លែងការណ៍ជាសាធារណៈដ៏មានសក្តានុពលមួយស្តីពីកូនក្តីរបស់ខ្លួន ដែលធ្វើឡើងដោយនាយករដ្ឋមន្ត្រី **ហ៊ុន សែន**។ យោងតាមមេធាវីការពារក្តីលោក **នួន ជា** បានឲ្យដឹងថា អ្នករាយការណ៍ព័ត៌មានបានដកស្រង់សម្តីនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងសន្និសិទការសែតមួយនៅប្រទេសវៀតណាម ដោយបានពិពណ៌នាសេចក្តីថ្លែងការណ៍របស់លោក **នួន ជា** ដែលបានផ្តល់ទៅតុលាការកាលពីខែធ្នូ ថាជា “កាបោកប្រាស់” ។ ជាមួយនឹងការថ្លែងពោរពេញដោយអារម្មណ៍ខឹងសម្បារ លោកមេធាវី **ផេស្តមិន** បានបន្តចង្អុលបង្ហាញថា ថ្មីៗនេះ លោកនាយករដ្ឋមន្ត្រីបានហៅលោក **នួន ជា** ថាជា “ជាឃាតករ” និងជាជនដៃដល់នៃការប្រល័យពូជសាសន៍។ មេធាវីបានតវ៉ាថា ការថ្លែងបែបនេះធ្វើឡើងពីសំណាក់មន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាលណាម្នាក់ថា លោក **នួន ជា** ជាជនមានទោសជាការការរំលោភបំពាននូវសិទ្ធិកូនក្តីរបស់គាត់យ៉ាងសម្ងៃង ជាពិសេសនោះ សិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះមួយប្រកបដោយយុត្តិធម៌។ លោកមេធាវីនិយាយដោយការមិនពេញចិត្តថា “វាមិនអាស្រ័យលើនាយករដ្ឋមន្ត្រីជាអ្នកសម្រេចថា តើកូនក្តីរបស់ខ្ញុំមានទោស ឬអត់ “ក៏ប៉ុន្តែវាអាស្រ័យលើចៅក្រមនៅក្នុងតុលាការនេះ”។ គាត់ក៏បានបន្តថ្លែងថា ការធ្វើការកំណត់សម្គាល់ដោយមន្ត្រីបម្រើការងាររាជការជាន់ខ្ពស់របៀបនេះ នេះហាក់បីដូចជាដាក់សម្ពាធទៅលើតុលាការនេះអញ្ចឹង ឬក៏ជាការជំរុញឲ្យតុលាការដទៃទៀតធ្វើការផ្តន្ទាទោសឲ្យខានតែបានលើកូនក្តីរបស់គាត់។ ទង្វើបែបនេះ នាំឲ្យជះឥទ្ធិពលអវិជ្ជមានដល់ឯករាជ្យភាពនៃអង្គចៅក្រម ជាពិសេសនោះគឺ ភាពទន់ខ្សោយដ៏ល្បីល្បាញដែលបានកើតមាននៅក្នុងប្រព័ន្ធតុលាការកម្ពុជា។ មធ្យោបាយដែលមេធាវី **ផេស្តមិន** បានស្នើសុំឲ្យតុលាការនេះដោះស្រាយជាបន្ទាន់ គឺត្រូវធ្វើការឆ្លើយតបទៅនឹងសេចក្តីថ្លែងការណ៍របស់លោកនាយកមន្ត្រីឲ្យខ្លាំងៗ ជាពិសេស មេធាវីបានស្នើសុំឲ្យតុលាការធ្វើការថ្កោលទោសយ៉ាងធ្ងន់ធ្ងរប្រឆាំងនឹងសេចក្តីថ្លែងការណ៍របស់លោក **ហ៊ុន សែន** និងថែមទាំងបានស្នើសុំទៅនាយករដ្ឋមន្ត្រីមិនឲ្យធ្វើសេចក្តីថ្លែងការណ៍របៀបនេះតទៀតនៅពេលក្រោយៗទៀត ។ លោកមេធាវីការពារក្តី ក៏បានក្រើនរម្លឹកទៅកាន់អង្គជំនុំជម្រះថា វាជាការសំខាន់ណាស់សម្រាប់លោក លោកស្រី ចៅក្រម រួមគ្នាការពារនូវ “សុចរិតភាពរបស់តុលាការនេះ” នៅក្នុងការវិនិច្ឆ័យលើសេចក្តីថ្លែងការណ៍នោះ ។

អង្គជំនុំជម្រះ បានអនុញ្ញាតឲ្យលោក **ផេស្តមិន** បន្តធ្វើការជំទាស់របស់គាត់លើអាកប្បកិរិយារបស់នាយករដ្ឋមន្ត្រី ក៏ប៉ុន្តែវាចម្លែកត្រង់ថា តុលាការមិនបានចាត់ការដោះស្រាយពីភាពអយុត្តិធម៌ណាមួយ ហើយក៏មិនបានលើកឡើងនូវមធ្យោបាយនានាដើម្បីដោះស្រាយបញ្ហានេះដែរ ។ តាមការស្មាន តុលាការប្រហែលជាមិនឃើញថាមានគុណសម្បត្តិអ្វី (ផលល្អណាមួយ) ចំពោះការជំទាស់របស់មេធាវីការពារក្តី ដូចនេះហើយបានជាតុលាការមិនជ្រើសយកការស្តីបន្ទោសជាសាធារណៈទៅកាន់នាយករដ្ឋមន្ត្រី។

ទោះយ៉ាងណាក៏ដោយ អង្គចៅក្រមមិនបានពន្យល់ ឬផ្ដល់នូវការឆ្លើយតបចំពោះសេចក្ដីព្រួយបារម្ភដែលលើកឡើងដោយមេធាវីការពារក្ដីឡើយ ។ បន្ទាប់ពីអនុញ្ញាតឲ្យមេធាវីការពារក្ដីឡើងថ្លែងហើយ អង្គជំនុំជម្រះ ក៏បានប្រកាសបន្តដំណើរការនីតិវិធីធម្មតា ដូចគ្មានអ្វីបានកើតឡើង ។

បើយោងតាមទស្សនវិស័យនៃការគ្រប់គ្រងសវនាការវិញ វាហាក់បីដូចជា បានចង្អុលប្រាប់ឲ្យតុលាការបង្ហាញនូវការយកចិត្តទុកដាក់ឲ្យបានហ្មត់ចត់នូវបញ្ហាដែលបានភាគីការពារក្ដីបានលើកឡើងម្ដងជាពីរដង ហើយ និងនៅតែបន្តធ្វើដូចនេះដរាបណាមិនមានការឆ្លើយតប ។ ដូច្នេះហើយ ការអវត្តមាននៃការប្រកាសដ៏ច្បាស់លាស់មួយពីតុលាការទោះតាមវិធីណាក៏ដោយ ទំនងជានឹងនៅតែបន្តលើកឡើងនូវបញ្ហាដដែលនោះនៅក្នុងសវនាការខាងមុខៗទៀត ។

## *ជំពូកទី៤ ៖* ការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

លោក **រ៉ម យុន** និងលោក **ក្លាន ហ្វីត** ជាដើមបណ្ដឹងរដ្ឋប្បវេណីពីរនាក់ដំបូងគេដែលបង្ហាញខ្លួននៅមុខអង្គជំនុំជម្រះនៅក្នុងសំណុំរឿង ០០២។ ការផ្ដល់សក្ខីកម្មរបស់ពួកគាត់ បានជួបប្រទះនូវបញ្ហាមួយចំនួនបានកើតមានឡើង រួមបញ្ចូលទាំងខ្វះការណែនាំច្បាស់លាស់ពីមេធាវីតំណាងរបស់ពួកគាត់ និងភាពសំខាន់ៗនៅក្នុងការចង្អុលបង្ហាញនូវតម្រូវការពិសេសដែលទាំងពួកគាត់ និងដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងទៀត ដែលអាចមាននៅពេលដែលពួកគេទាំងអស់នេះ បានមកផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការ ដូចជាចង់ឲ្យមានសេវាកម្មបកប្រែជាភាសាដើមរបស់ពួកគាត់ ហើយក៏ដូចជាការយកចិត្តទុកដាក់លើសុខភាពជាដើម ។ល។

### ក. ការទាមទារឲ្យមានសំណង

សវនាការនៅសប្ដាហ៍នេះ បានជំរុញឲ្យមានការគិតពីក្ដីព្រួយបារម្ភចំពោះភាពពេញលេញ នៃសំណងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់ការជំនុំជម្រះ ក៏ដូចជាការពារផលប្រយោជន៍ដើមបណ្ដឹងរដ្ឋប្បវេណីដោយមេធាវីតំណាងរបស់ពួកគាត់។ យោងតាមវិធាន ២៣ នៃវិធានផ្ទៃក្នុងរបស់ **អ.វ.ត.ក** គោលបំណងនៃការបង្កើតឲ្យមានសកម្មភាពរបស់បណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខ **អ.វ.ត.ក** គឺមានពីរ៖ ទី១ ជួយសហព្រះរាជអាជ្ញាដោយចូលរួមនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងជនជាប់ចោទ និងទី២ ស្វែងរកសំណងផ្លូវចិត្ត និងជាសមូហភាព។ ខណៈពេលដែលដើមបណ្ដឹងរដ្ឋប្បវេណីទាំងពីររូបគឺលោក **រ៉ម យុន** និងលោក **ក្លាន ហ្វីត** អាចនឹងផ្ដល់នូវទិដ្ឋភាពដែលបានកើតឡើង គាំទ្រទៅលើអង្គហេតុនៃសំណុំរឿងទាក់ទងនឹងគោលបំណងទី១ (គាំទ្រសហព្រះរាជអាជ្ញា) មេធាវីតំណាងរបស់ពួកគាត់ គួរតែបានធ្វើការសួរនាំកូនក្ដីខ្លួនឲ្យបានច្រើនជាងនេះ ទាក់ទងនឹងសេចក្ដីថ្លែងការណ៍បឋមរបស់កូនក្ដីខ្លួនស្ដីពីការទាមទារសំណងផ្លូវចិត្ត និងសមូហភាព ដើម្បីបំពេញន័យដល់គោលបំណងទី២។ វាមិនមែនជាការជួយដល់ដើមបណ្ដឹងរដ្ឋប្បវេណីឡើយ ពីព្រោះបន្ទាប់ពីផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ភាគីការពារក្ដីនិយាយបានថា ពួកគេមិនបានផ្ដល់ភស្តុតាងអ្វីស្ដីពីទុក្ខវេទនា និងការខូចខាតដែលបានកើតឡើងក្នុង

របបនោះទេ ។ ត្រង់ចំណុចនេះ ត្រូវបានមេធាវី **ផេស្តមិន** ទាញយកការផ្តល់សក្ខីកម្មរបស់លោក **រ៉េម យុន** ជាឧទាហរណ៍ ។ នៅពេលដែលត្រូវបានសួរអំពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងការស្នើនូវសំណងនានារបស់គាត់ លោក **ក្លាន ហ្វីត** បាននិយាយប្រាប់ថា គាត់មិនយល់ថា តើ"ដើមបណ្តឹងរដ្ឋប្បវេណី" ជាអ្វីនោះទេ ហើយគាត់ក៏មិនបានដាក់ពាក្យប្តឹងដែរ ។ លោក **ក្លាន ហ្វីត** បាននិយាយបន្ថែមទៀតថា លោកមិនចង់បានអ្វីអំពីជនជាប់ចោទទេ ក៏ប៉ុន្តែគ្រាន់តែចង់ដឹងថា ហេតុអ្វីបានជាអង្គការមិនពេញចិត្តជាមួយការងាររបស់គាត់ ទោះបីជាគាត់ខំប្រឹងធ្វើការនឿយហត់យ៉ាងណាក៏ដោយ។

ដោយសារតែកិច្ចដំណើរការនីតិវិធីសវនាការនឹងនៅតែមានជាហូរហែ វាទាមទារឲ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីផ្តល់នូវការយកចិត្តទុកដាក់ជាបឋម ក្នុងការធានាឲ្យបានច្បាស់ថា កូនក្តីរបស់ពួកគេបានយល់ពីរឿងរ៉ាវ និងគោលបំណងចំពោះវត្តមាននៃការចូលរួមរបស់ពួកគាត់នៅក្នុងដំណើរការនីតិវិធី ហើយទី២ ទៀតការនាំមុខដើមបណ្តឹងរដ្ឋប្បវេណីតាមរយៈសំណួរទាំងឡាយក្នុងបន្ទប់សវនាការ ដែលជួយជំរុញឲ្យការទាមទាររបស់កូនក្តីកាន់មានប្រសិទ្ធភាព ឆ្លើយតបនឹងការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងការទាមទារសំណងរបស់ពួកគាត់ផងដែរ។ បញ្ហាដែលបានលើកឡើងទាំងនេះ អាចឆ្លុះបង្ហាញឲ្យឃើញនូវផលលំបាកជាក់លាក់ និងគួរពិចារណាចំពោះធនធានមានកម្រិតរវាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងរបស់ពួកគេ ។

### ខ. ការផ្តល់ជំនួយដល់ដើមបណ្តឹងរដ្ឋប្បវេណី

ទាំងលោក **ក្លាន ហ្វីត** និងលោក **រ៉េម យុន**សុទ្ធតែបានទទួលការជួយគាំពារពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងអំឡុងនៃការផ្តល់សក្ខីកម្មរបស់ពួកគាត់។ ការយកចិត្តទុកដាក់ជាពិសេសចំពោះពួកគាត់ទាំងពីរត្រូវបានធ្វើឡើងពីព្រោះភាសាដើមរបស់ពួកគាត់គឺ "ការចុក" មិនមែនភាសាខ្មែរទេ។ មន្ត្រីអង្គភាពគាំពារសាក្សី និងអ្នកជំនាញបានជួយសម្រួលធ្វើយ៉ាងណាដើម្បីធានាថាដើមបណ្តឹងរដ្ឋប្បវេណីទាំងពីរយល់នូវសំណួរដែលបានសួរទៅកាន់ពួកគាត់ ហើយម្យ៉ាងវិញទៀត ក៏បានយកចិត្តទុកដាក់ផងដែរលើបញ្ហាសុខភាពរបស់ពួកគាត់។

## *ជំពូកទី៥ ៖* ការគ្រប់គ្រងសវនាការ

នៅក្នុងសប្តាហ៍ទីពីរនៃសវនាការលើភស្តុតាង បានឆ្លុះបង្ហាញនូវបញ្ហាពីរដែលទំនងជាអាចកើតឡើងម្តងទៀត ចំពោះបរិបទនៃការគ្រប់គ្រងសវនាការ៖ យុទ្ធសាស្ត្រនៅក្នុងការចាត់ចែងពេលវេលារបស់អង្គជំនុំជម្រះ ការពិចារណាលើទំហំ និងភស្តុតាងឯកសារដែលអាចប្រើប្រាស់បាន ព្រមទាំងសក្ខីកម្មជាភស្តុតាងដែលរំពឹងទុកថានឹងត្រូវដាក់បង្ហាញនៅតុលាការ ហើយនិងបញ្ហាចុងក្រោយគឺ អាកប្បកិរិយាបំពារបំពាននៅក្នុងបន្ទប់សវនាការ ដែលនាំឲ្យមានការជជែករកខុសត្រូវយ៉ាងក្តៅគគុកពីសំណាក់ភាគី។

### ក. វត្តមានជនជាប់ចោទ និងមេធាវីការពារក្តី

ជនជាប់ចោទទាំងបីរូប មានវត្តមាននៅពេលចាប់ផ្តើមនៃវគ្គដំបូងជារៀងរាល់ថ្ងៃនៃសវនាការនីតិវិធី ប៉ុន្តែបន្ទាប់ពីវគ្គព្រឹកបានបញ្ចប់ទៅនៅថ្ងៃទី១១ និង១២ ខែមករា អង្គជំនុំជម្រះ បានអនុញ្ញាតឲ្យលោក **អៀង សារី** និងលោក **នួន ជា** ចូលរួមនីតិវិធីសវនាការពីបន្ទប់ឃុំឃាំងតាមរយៈប្រព័ន្ធសោតទស្សន៍ ។ មានតែលោក **ខៀវ សំផន** ទេដែលមានវត្តមានក្នុងបន្ទប់សវនាការគ្រប់ពេលទាំងអស់នៃដំណើរការនីតិវិធី ។ មេធាវីអន្តរជាតិការពារក្តីលោក **ខៀវ សំផន** បានអវត្តមាននៅពេញមួយសប្តាហ៍ ក៏ប៉ុន្តែវាហាក់ដូចជាមិនមានភាពចាំបាច់អ្វីឡើយក្នុងសប្តាហ៍នោះ។

## ខ. កាលវិភាគតុលាការ

កាលវិភាគបានកំណត់ថា នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ អង្គជំនុំជម្រះ បានផ្តល់ដំបូន្មានឲ្យគ្រប់ភាគីចេះបត់បែនទៅតាមកាលវិភាគសវនាការ។ ការកំណត់បែបនេះ ត្រូវបានយកទៅអនុវត្តភ្លាមៗក្នុងសប្តាហ៍នេះ ខណៈដែលដើមបណ្តឹងរដ្ឋប្បវេណីទាំងពីរនាក់នេះ មិនអាចផ្តល់សក្ខីកម្មបាន ពីព្រោះតែសុខភាពលោក **រ៉ម យុន** មិនអំណោយផល។ ដើម្បីចង្អុលបង្ហាញពីការចេះបត់បែនតាមកាលវិភាគ ដោយអង្គជំនុំជម្រះបានកោះហៅលោក **នួន ជា** មកផ្តល់សក្ខីកម្មជំនួសវិញម្តង។ មិនមានអ្វីគួរឲ្យភ្ញាក់ផ្អើលទេ បើភាគីមិនអាចធ្វើតាមការបត់បែនបានទាំងស្រុងតាមការចាត់ចែងរបស់អង្គជំនុំជម្រះ ក៏ប៉ុន្តែពួកគេក៏ត្រូវអត់ទ្រាំទទួលយកនូវការផ្លាស់ប្តូរផ្សេងៗនៅក្នុងកាលវិភាគប្រចាំសប្តាហ៍ផងដែរ។ ទោះជាយ៉ាងនេះក្តី នៅពេលសវនាការបានដំណើរការ អង្គជំនុំជម្រះ ត្រូវចេះគ្រប់គ្រងសវនាការប្រកបដោយតម្លាភាព និងមានការរៀបចំឲ្យមានរបៀបរៀបរយ។ កិច្ចការទាំងនេះ មានសារៈសំខាន់ណាស់ ដើម្បីបញ្ចៀសស្ថានភាព នៅពេលដែលភាគីមិនអាចដឹងខ្លួនជាមុនបានថាតើមានអ្វីនឹងអាចកើតឡើងនៅក្នុងវគ្គបន្តបន្ទាប់ទៀតនៃថ្ងៃដូចគ្នានេះ ។ ជាឧទាហរណ៍ មានពេលមួយនោះ លោក **វ៉ាយដ៍ ដេស្វាងល** បានសួរទៅកាន់អង្គជំនុំជម្រះ ថាតើកាលវិភាគតុលាការនឹងត្រូវធ្វើអ្វីទៀតបន្ទាប់ពីសម្រាកថ្ងៃត្រង់ ឬក៏ត្រូវបោះបង់ពេលវេលានេះចោល ហើយធ្វើការសម្រាកមុនពេលកំណត់ ព្រោះតែមិនមានសាក្សីបម្រុង។

## គ. អាកប្បកិរិយាក្នុងបន្ទប់សវនាការ

បរិយាកាសតប់ប្រមល់នៅក្នុងបន្ទប់សវនាការ ជាលទ្ធផលនាំឲ្យមានឥរិយាបទមិនសមរម្យខ្លះៗរវាងភាគីនៃសំណុំរឿង ។ រឿងរ៉ាវមួយត្រូវបានកើតឡើងនៅពេលដែលជនជាប់ចោទ **នួន ជា** ហាក់ដូចជាចំអកលើមតិយោបល់របស់សហព្រះរាជអាជ្ញា **លីសាក់** ដែលបានស្នើឲ្យអង្គជំនុំជម្រះជួយផ្តល់ដំបូន្មានដល់ជនជាប់ចោទ ។ ដោយចេតនាដើម្បីការពារកូនក្តីរបស់ខ្លួនអំពីអ្វីដែលលោកឃើញជាសំណួរនាំឲ្យមានការភាន់ច្រឡំ មេធាវី **សុន អរុណ** បានប្រើប្រាស់ភាសាដែលអង្គជំនុំជម្រះចាត់ទុកថាជាភាសាមិនសមរម្យ ។ លោកមេធាវី ហាក់ដូចជាមិនបានយល់ ឬអាចនឹងធ្វើសេចក្តីថ្លែងការណ៍ខុស ដោយការដកស្រង់ចេញពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះក្នុងការផ្តល់ទម្ងន់លើការលើកឡើងរបស់ខ្លួន ។ ការថ្លែងរបស់លោក **សុន អរុណ** នេះ បាននាំឲ្យមានការព្រមានពីសំណាក់ប្រធានតុលាការ លោកចៅក្រម **និល ណុន** ថាមិនឲ្យប្រើប្រាស់ "ពាក្យមិនល្អ" ជាមួយនឹងសហព្រះរាជ

អាជ្ញាទេ។ ទោះបីជាយ៉ាងនេះក្តី អ្វីដែលចាប់អារម្មណ៍នោះ គឺការស្តីបន្ទោសរបស់ប្រធានចៅក្រមចំពោះសេចក្តីថ្លែងការណ៍របស់មេធាវីរូបនេះ ដូចជាធ្វើឡើងជាមួយសំលេងគ្រេវគ្រោធ ហើយការថ្លែងជាហូរហែបន្តពីនេះហាក់ដូចជាគ្មានភាពចាំបាច់សម្រាប់ប្រធានតុលាការក្នុងការត្រូវលើកឡើងឡើយ។

ភាពតានតឹងនៃការប្រកែកតវ៉ានៅចំពោះមុខអង្គជំនុំជម្រះ បានការកើនឡើងក្នុងសប្តាហ៍នេះ។ ខណៈដែលវាគួរឲ្យចាប់អារម្មណ៍នៅក្នុងការមើលឃើញភាគីចូលរួមយ៉ាងផុសផុលនៅក្នុងដំណើរការនីតិវិធី ការសង្កេតដោយភាគីស្តីពីឥរិយាបទនៅក្នុងបន្ទប់សវនាការវិញ គឺត្រូវតែមានចំពោះការប្រព្រឹត្តទៅនៃសវនាការ (ភាគីត្រូវចំណាយពេលតាមដានលើការវិវឌ្ឍន៍នៃសំណុំរឿង ចៀសវាងការធ្វើសម្លាងមិនត្រឹមត្រូវ)។

## ឃ. ការគ្រប់គ្រងពេលវេលា និងកាលវិភាគ

នៅសប្តាហ៍នេះអង្គជំនុំជម្រះ បានចាប់ផ្តើមនីតិវិធីបួន ឬ ៥នាទី ក្រោយម៉ោងប្រាំបួន។ សវនាការនៅថ្ងៃពុធ បានបញ្ចប់មុនពេលកំណត់ បន្ទាប់ពីការផ្តល់សក្ខីកម្មរបស់លោក **ភ្លាន ហ្វីត**។ ដូចគ្នាផងដែរ អង្គជំនុំជម្រះបានផ្អាកសវនាការមុនពេលកំណត់នៅពេលដែលលោក **ខៀវ សំផន** មិនព្រមធ្វើការអត្ថាធិប្បាយលើការដកស្រង់ដែលអានដោយចៅក្រម **ឡាវែន** ហើយក៏ដោយសារតែសប្តាហ៍នេះ អង្គជំនុំជម្រះ មិនបានត្រៀមទុកសាក្សីបម្រុងផ្សេងទៀតដែរ។

| កាលបរិច្ឆេទ | ចាប់ផ្តើម | ការសម្រាកពេលព្រឹក | អាហារថ្ងៃត្រង់ | សម្រាកពេលរសៀល | បិទសវនាការ | ចំនួនម៉ោងសរុប |
|---|---|---|---|---|---|---|
| ថ្ងៃអង្គារ ១០/០១/១២ | ៩:០៧ | ១០:៣៨-១១:០៣ | ១២:២៤-១៣:៣៩ | ១៤:៥២-១៥:១១ | ១៦:១២ | ៥ម៉ោង និង ៦នាទី |
| ថ្ងៃពុធ ១/០១/១២ | ៩:០៨ | ១០:៣១-១១:០៤ | ១២:០៥-១៣:៣៣ | ១៥:០០-១៥:២៣ | ១៥:៣៧ | ៤ម៉ោង និង ៣នាទី |
| ថ្ងៃព្រហស្បតិ៍ ១២/០១/១២ | ៩:០៩ | ១០:៣១-១០:៥១ | ១២:០៩-១៣:៣៥ | -- | ១៥:០០ | ៤ម៉ោង និង ៥នាទី |
| **ចំនួនម៉ោងជាមធ្យមក្នុងសវនាការមួយវគ្គ៖ ៤ម៉ោងនិង២៤នាទី**<br>**ចំនួនម៉ោងសរុបក្នុងសប្តាហ៍នេះ ៖ ១៣ម៉ោង និង១៤នាទី**<br>**១៣ថ្ងៃ និង ៤សប្តាហ៍** | | | | | | |

* This issue of KRT Trial Monitor was authored by Mary Kristerie A. Baleva, Samuel Gilg, Princess Principe, Noyel Ry, Kimsan Soy, Penelope Van Tuyl and Flavia Widmer as part of AIJI's KRT Trial Monitoring and Community Outreach Program. KRT Trial Monitor reports on Case 002 are available at <www.krtmonitor.org>, http://forum.eastwestcenter.org/Khmer-Rouge-Trials/ and <http://socrates.berkeley.edu/~warcrime/>. AIJI is a collaborative project between the Eas-West Center, in Honolulu, and the University of California, Berkeley War Crimes Studies Center. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia. The Program is funded by the Open Society Foundation, the Foreign Commonwealth Office of the British Embassy in Phnom Penh, and the Embassy of Switzerland in Bangkok.

1 This is in reference to Nuon Chea's answer to a question posed by Judge Cartwright in December 2011.

2 It appears that the Nuon Chea Defense did not examine both civil parties as a standing objection, on the ground that unless the civil parties taken an oath, their testimony should be limited to the damage they have allegedly suffered and should not cover facts. *See* CASE 002 KRT TRIAL MONITOR Issus No. 1 (week ending 8 December 2011).

3 The transcript of the hearing on 6 December refers to the location of "O Plang," the location of K-5 as "Chong Ou Blang." See Trial Chamber. Transcript of Hearing (6 December 2011). E1. 17.1. Lines 5-6. 82.

4 *See* CASE 002 KRT TRIAL MONITOR Issue No. 2 (week ending 15 December 2011).